ធនាគារជាតិ នៃ កម្ពុជា

ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.

# ព្រឹត្តិបត្រប្រចាំត្រីមាស

## ត្រីមាសទី២ ឆ្នាំ២០២៤



ចេញផ្សាយតាមប្រកាសលេខ
ធ៦-០១១-១២៣ ប្រ.ក
ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១

លេខ ៧៩

# អារម្ភកថា



**លោកជំទាវបណ្ឌិត ជា សិរី**
**ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**

**ប្រិយមិត្តអ្នកអានជាទីមេត្រី!**

នៅត្រីមាសទី២ ឆ្នាំ២០២៤នេះ សេដ្ឋកិច្ចពិភពលោកនៅរក្សាបានភាពធន់ បើទោះបីជាបានប្រឈមនឹងកម្រិតខ្ពស់នៃអត្រាការប្រាក់គោល ការអូសបន្លាយសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ជម្លោះនៅមជ្ឈិមបូព៌ា បញ្ហាដក់សល់ពីជំងឺកូវីដ-១៩ ការកើនឡើងនៃការបែងចែកភូមិសាស្ត្រសេដ្ឋកិច្ចក៏ដោយ។ ប្រទេសដែលមានទំហំសេដ្ឋកិច្ចធំៗក្នុងតំបន់នានា មានកំណើនខុសៗគ្នា ដូចជា សហរដ្ឋអាមេរិករក្សាបានកំណើនល្អគាំទ្រជាចម្បងដោយការកើនឡើងនៃតម្រូវការក្នុងស្រុក ដោយឡែកតំបន់អឺរ៉ូមានកំណើនទាប ដោយសារផលប៉ះពាល់ពីការអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែនគួបផ្សំនឹងការរឹតត្បិតនៃការផ្តល់ឥណទានទៅកាន់វិស័យសំខាន់ៗ ជាពិសេសវិស័យសំណង់ ស្របពេលដែលប្រទេសចិនមានកំណើនយឺត ដោយសារតែភាពទន់ខ្សោយនៃវិស័យអចលនទ្រព្យ ការថមថយនៃចំណាយក្នុងស្រុក និងកម្រិតខ្ពស់នៃបំណុលសាធារណៈ។ ប្រទេសក្នុងតំបន់អាស៊ានសម្រេចបានកំណើនល្អគាំទ្រដោយការកើនឡើងនៃការនាំចេញ វិស័យទេសចរណ៍ និងតម្រូវការក្នុងស្រុក។

នៅកម្ពុជា សកម្មភាពសេដ្ឋកិច្ចក្នុងវិស័យចម្បងៗបានកើនឡើងក្នុងល្បឿនខុសគ្នា ប៉ុន្តែជារួមបានជំរុញឱ្យសេដ្ឋកិច្ចបន្តងើបឡើង ដែលគាំទ្រជាចម្បងដោយការស្ទុះឡើងនៃវិស័យកម្មន្តសាលកាត់ដេរ និងការបន្តងើបឡើងនៃវិស័យទេសចរណ៍ ទោះបីជាវិស័យសំណង់និងអចលនទ្រព្យបន្តមានកំណើនទន់ខ្សោយក៏ដោយ។ អតិផរណាមានកម្រិតទាបជាមធ្យមត្រឹម ០,៧% ដោយសារការធ្លាក់ចុះនៃថ្លៃក្រុមទំនិញ និងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ ស្របពេលដែលអតិផរណាម្ហូបអាហារ និងអតិផរណាស្នូលមានកម្រិតទាប ក្នុងបរិការណ៍ដែលកំណើនផលិតកម្មក្នុងស្រុកមានភាពល្អប្រសើរគួបផ្សំនឹងការថយចុះថ្លៃដើមផលិតដូចជា ជីកសិកម្ម និងប្រេងឥន្ធនៈ។ អត្រាប្តូរប្រាក់រៀលធៀបនឹង

ដុល្លារអាមេរិកបន្តមានភាពល្អប្រសើរក្នុងកម្រិតជាមធ្យម ៤.០៨០ រៀលក្នុងមួយដុល្លារអាមេរិក ដោយប្រាក់រៀលបានថយថ្លៃ ០,២% ធៀបនឹងត្រីមាសមុន។ ជាមួយគ្នានេះ ទុនបម្រុងអន្តរជាតិក៏ត្រូវបានគរពូនឱ្យស្ថិតក្នុងកម្រិតមួយសមស្រប ដែលបានពង្រឹងជំនឿទុកចិត្តវិនិយោគិននិងសាធារណជនមកលើស្ថិរភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាតិឱ្យកាន់តែរឹងមាំថែមទៀត។

ប្រព័ន្ធធនាគាររក្សាបានភាពធន់ និងបន្តមានវឌ្ឍនភាព ដោយទ្រព្យសកម្មរបស់ប្រព័ន្ធធនាគារមានកំណើន ៦,៩% ដល់ ៣៥៧៩,៤ ទ្រីលានរៀល ស្មើ ៨៧,៤ ប៊ីលានដុល្លារអាមេរិក ដែលក្នុងនោះទ្រព្យសកម្មវិស័យធនាគារកើនឡើង ១៥,៨%។ ទន្ទឹមនេះ ការអភិវឌ្ឍនិងការធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់ប្រកបដោយសុវត្ថិភាព ប្រសិទ្ធភាព និងនវានុវត្តន៍ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងសេដ្ឋកិច្ចឌីជីថល ព្រមទាំងបានជំរុញបរិយាបន្នហិរញ្ញវត្ថុ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ជាក់ស្តែង ដើម្បីសម្រួលដល់ការធ្វើពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ និងការផ្ទេរប្រាក់ឆ្លងដែនឱ្យមានភាពងាយស្រួលឆាប់រហ័ស និងសុវត្ថិភាព ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការគម្រោងទូទាត់ឆ្លងដែនជាមួយប្រទេសថៃ ឡាវ វៀតណាម និងក្រុមហ៊ុនអន្តរជាតិយូញៀនផេ ព្រមទាំងកំពុងពង្រីកគម្រោងទូទាត់ឆ្លងដែនជាមួយប្រទេសផ្សេងទៀតក្នុងតំបន់ និងដៃគូសហការនានា ដូចជា ប្រទេសចិន ជប៉ុន ឥណ្ឌា កូរ៉េ សិង្ហបុរី ម៉ាឡេស៊ី និងក្រុមហ៊ុនអាលីផេ ជាដើម។

**ប្រិយមិត្តអ្នកអានជាទីមេត្រី!**

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមផ្សព្វផ្សាយព្រឹត្តិបត្រប្រចាំត្រីមាសទី២ ឆ្នាំ២០២៤ ដោយរួមបញ្ចូលនូវព័ត៌មានសំខាន់ៗ ដូចជា៖ i/-ស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធធនាគារ ii/-បទប្បញ្ញត្តិថ្មីៗ និង iii/-សេចក្តីប្រកាសព័ត៌មាន។ល។ ខ្ញុំសង្ឃឹមថា ព្រឹត្តិបត្រដែលប្រិយមិត្តអ្នកអានទាំងអស់ មាននៅក្នុងដៃនាពេលនេះនឹងរួមចំណែកបង្កើតចំណេះដឹងផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដូចជា ការស្វែងយល់ពីគោលនយោបាយ និងសកម្មភាពការងារថ្មីៗរបស់ធនាគារជាតិនៃកម្ពុជា។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់មន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា ដែលបាននិងកំពុងបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ព្រមទាំងក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធទាំងអស់ដែលបានរួមចំណែកអភិវឌ្ឍវិស័យធនាគារនៅកម្ពុជា ឱ្យរីកចម្រើនឡើងជាលំដាប់ និងបោះជំហានទៅមុខយ៉ាងស្វាហាប់ ក្នុងការជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយភាពរឹងមាំ ចីរភាព និងបរិយាបន្ន។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រិយមិត្តអ្នកអានទាំងអស់ សូមជួបប្រទះនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**

# មាតិកា

**អារម្ភកថា**.......................................................................... i-ii

## ផ្នែកទី១: រូបថត និងសុន្ទរកថារបស់ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា

១.១. សុន្ទរកថា លោកជំទាវបណ្ឌិត ជា សិរី ថ្លែងក្នុងកម្មវិធី "ខួប ៣០ឆ្នាំ នៃការបង្កើតសមាគមធនាគារនៅកម្ពុជា"........................................ ១

១.២. សុន្ទរកថាបើក លោកជំទាវបណ្ឌិត ជា សិរី ថ្លែងក្នុងពិធីបើកសិក្ខាសាលាផ្សព្វផ្សាយស្ដីពី "របាយការណ៍ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុឆ្នាំ២០២៣" ........................................ ៥

១.៣. សុន្ទរកថា លោកជំទាវបណ្ឌិត ជា សិរី ថ្លែងក្នុងពិធីក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់រវាង ធនាគារជាតិនៃកម្ពុជា និងក្រសួងកិច្ចការនារី ស្ដីពី ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី ........................................ ១០

## ផ្នែកទី២: សេចក្ដីប្រកាសព័ត៌មាន

២.១. សេចក្ដីប្រកាសព័ត៌មានរួម ស្ដីពី ការទទួលបានពានរង្វាន់សកលថ្នាក់ក្រសួង (Global Summit of Women 2024 Roundtable Ministerial Award) លើ "គម្រោងដែលមានផលជះវិជ្ជមានចំពោះស្ត្រី និងក្មេងស្រី" តាមរយៈការប្រើប្រាស់ប្រព័ន្ធទូទាត់ "បាគង" ក្នុងកិច្ចប្រជុំកំពូលស្ត្រីពិភពលោក ឆ្នាំ២០២៤ ទីក្រុងម៉ាឌ្រីដ ប្រទេសអេស្ប៉ាញ........................................ ១៤

## ផ្នែកទី៣: សកម្មភាពថ្នាក់ដឹកនាំ

៣.១. លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញចុះហត្ថលេខាលើអនុស្សរណៈយោគយល់ទ្វេភាគី ស្ដីពី "កិច្ចសហប្រតិបត្តិការទូទាត់ឆ្លងដែនតាមឃ្យូអរកូដ" នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ.. ១៦

៣.២. លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញចូលរួមក្នុងពិធីប្រកាសដាក់ឱ្យដំណើរការគម្រោងថ្នាលច្រករបៀងតម្លាភាពហិរញ្ញវត្ថុ រវាងកម្ពុជា និងសិង្ហបុរី ........................................ ១៨

៣.៣. ឯកឧត្តម ជា ចាន់តូ អញ្ជើញជាអធិបតីក្នុងពិធីទទួលទេវតាឆ្នាំថ្មី ព្រះនាមមហោទរាទេវី ព្រមទាំងសូត្រមន្តចម្រើនព្រះបរិត្តពុទ្ធជ័យមង្គល និងរាប់បាត្រព្រះសង្ឃ ........................................ ១៩

៣.៤. លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញជាអធិបតីចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីពី "កិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រសម្រាប់ហិរញ្ញប្បទានឌីជីថលបៃតងនៅកម្ពុជា" ........ ២០

៣.៥. លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញចូលរួមក្នុងកិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលនៃប្រទេសនិយាយភាសាបារាំង........ ២២

៣.៦. លោកជំទាវបណ្ឌិត ជា សិរី និងលោកជំទាវ Natela Turnava ដឹកនាំគណៈប្រតិភូ ចូលរួមកិច្ចប្រជុំទ្វេភាគីរវាងធនាគារជាតិនៃកម្ពុជា និងធនាគារជាតិនៃហ្សកហ្ស៊ី........ ២៤

៣.៧. លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញចូលរួមជាវាគ្មិនកិត្តិយស ក្នុងវេទិកាពិភាក្សាក្រោមប្រធានបទ "មូលធនប្រកបដោយចីរភាព៖ ហិរញ្ញវត្ថុដែលគិតគូរពីបរិស្ថាន"........ ២៦

៣.៨. លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញចូលរួមជាវាគ្មិនក្នុងកិច្ចពិភាក្សានៃវេទិកា Nikkei Forum លើកទី២៩ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន ........ ២៨

៣.៩. លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញជាវាគ្មិនកិត្តិយសថ្លែងសុន្ទរកថាគន្លឹះ ស្តីពី "រូបិយប័ណ្ណឌីជីថល និងការធ្វើរៀលូបនីយកម្មនៅកម្ពុជាឡើងវិញ"........ ២៩

៣.១០. លោកជំទាវបណ្ឌិត ជា សិរី ដឹកនាំគណៈប្រតិភូធនាគារជាតិនៃកម្ពុជា ចូលរួមកិច្ចប្រជុំរួមថ្នាក់រដ្ឋមន្ត្រីនិងទេសាភិបាលធនាគារកណ្តាលអាស៊ាន+៣ ........ ៣១

៣.១១. លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ........ ៣៣

៣.១២. លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញបំពេញទស្សនកិច្ចនៅសារមន្ទីរសេដ្ឋកិច្ចនៃធនាគារកណ្តាលបារាំង ........ ៣៤

៣.១៣. លោកជំទាវបណ្ឌិត ជា សិរី ទទួលជួបសម្តែងការគួរសមនិងពិភាក្សាការងារជាមួយ ឯកឧត្តម Igor Driesmans ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំកម្ពុជា........ ៣៥

៣.១៤. លោកជំទាវបណ្ឌិត ជា សិរី អនុញ្ញាតឱ្យប្រធានសមាគមធនាគារនៅកម្ពុជា និងសមាជិកក្រុមប្រឹក្សាភិបាលថ្មីចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ ........ ៣៦

៣.១៥. លោកជំទាវបណ្ឌិត ជា សិរី ទទួលជួបក្រុមបេសកកម្មអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣........ ៣៧

៣.១៦. លោកជំទាវបណ្ឌិត ជា សិរី ជួបពិភាក្សាការងារជាមួយ ឯកឧត្តមបណ្ឌិត កៅ គឹមហួន អគ្គលេខាធិការអាស៊ាន........ ៣៨

៣.១៧. លោកជំទាវបណ្ឌិត ជា សិរី ជួបសម្តែងការគួរសមជាមួយ ឯកឧត្តម នង សាកល ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសបែលហ្ស៊ិក លុចសំបួ ហូឡង់ និងអូទ្រីស....................................... ៣៨
៣.១៨. លោកជំទាវបណ្ឌិត ជា សិរី អញ្ជើញជួបពិភាក្សាការងារជាមួយ ឯកឧត្តម លុយ ដាវីត........ ៤០
៣.១៩. លោកជំទាវបណ្ឌិត ជា សិរី អនុញ្ញាតឱ្យលោក Kenichiro Kashiwase ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ .................................................................... ៤២
៣.២០. លោកជំទាវបណ្ឌិត ជា សិរី ទទួលជួបសម្តែងការគួរសមនិងពិភាក្សាការងារជាមួយ ឯកឧត្តម Santo Darmosumarto.......................................................................... ៤៣

## ផ្នែកទី៤: តារាង (ភាសាខ្មែរនិងអង់គ្លេស)

៤.១. តារាងអត្រាប្តូរប្រាក់ប្រចាំខែ........................................................................... ៤៥
៤.២. ប្រាក់បញ្ញើនៅធនាគារទទួលប្រាក់បញ្ញើ និងបម្រែបម្រួលប្រចាំខែ ................................ ៤៧
៤.៣. ឥណទានផ្តល់ដោយធនាគារទទួលប្រាក់បញ្ញើតាមប្រភេទជំនួញ និងបម្រែបម្រួលប្រចាំខែ... ៤៨
៤.៤. ការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងអង្គការមិនមែនរដ្ឋាភិបាល ................. ៥០
៤.៥. ការជាត់ទាត់មូលប្បទានបត្រតាមរយៈសភាជាត់ទាត់............................................... ៥១
៤.៦. ប្រព័ន្ធធនាគារកម្ពុជា ........................................................................................ ៥៣

# សុន្ទរកថា
# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងកម្មវិធី "ខួប ៣០ឆ្នាំ នៃការបង្កើតសមាគមធនាគារនៅកម្ពុជា"

**Remarks by**

**H.E. Dr. Chea Serey, Governor of the National Bank of Cambodia**

**at the 30th Year Anniversary Celebration of**

**the Association of Banks in Cambodia**

Phnom Penh, 10th April 2024




**- Mr. Rath Sophoan, Representative of the Association of Banks in Cambodia,**

**- H.E. Dith Nita, Representative of the Cambodia Microfinance Association,**

**- Excellencies, Neak Oknhas, Distinguished Guests, Ladies and Gentlemen!**

Today, I am very delighted to be here with your Excellencies, Neak Oknhas, Distinguished Guests, Ladies and Gentlemen to preside over the 30th Year Anniversary Celebration of the Association of Banks in Cambodia (ABC).

I still remember that ABC was founded in 1994 and recognized by the Royal Government of Cambodia as a formal entity representing the banking sector in Cambodia. The establishment of this association aimed at enhancing the development of the financial system in Cambodia, protecting the legitimate interests of its members through close cooperation with local and international authorities, associations, organizations and relevant stakeholders, and serving as the facilitator between its member institutions and the National Bank of Cambodia (NBC). Taking this opportunity, I would like to extend my congratulations and appreciation to the board of directors, the management and all ABC staff in fulfilling their duties to achieve remarkable results and making a significant contribution to the development of Cambodia's banking sector over the past 30 years.

**Excellencies, Neak Oknhas, Distinguished Guests, Ladies and Gentlemen!**

Over these 30 years, Cambodia's banking system has rapidly developed, continued to maintain resilience and contributed to robust economic activities. At the same time, the growth in assets, credits and deposits in the banking sector has clearly demonstrated the confidence from the public and investors toward Cambodia's banking system and the economic recovery.

Along with this development, the NBC, as the supervisory authority, has been paying close attention in monitoring and supervising banking and financial institutions, as well as contributing to support the digitalization of Cambodia's socio-economy and facilitating trade and investment activities in line with the fast evolution of financial technology. In this regard, the NBC has continued to develop and modernize payment systems, such as the National Clearing House, the Fast Payment, the Online Banking, the Retail Pay, the Cambodian Shared Switch, especially the Bakong System, which all help to facilitate users and businessmen in performing money transfer transactions, as well as making local and cross-border payments via KHQR, with efficiency, security and low transaction costs. Currently, the National Bank of Cambodia has connected the payment system to countries such as Thailand, Malaysia, Laos, China and Vietnam which helps to facilitate trade, investment and tourism.

These achievements have essentially contributed to promoting financial inclusion in Cambodia. Based on the results of a Mobile Tracker Survey conducted by



UNCDF, the percentage of formal financial service users increased significantly from 59% in 2015 to 67% in 2021, which is closer to the target of 70% by 2025. At the same time, promoting financial literacy and consumer protection is the priority of the NBC in order to maintain robustness, resilience, sustainability and also the public and investors' confidence on the banking system. The NBC has cooperated with many ministries and development partners in promoting financial literacy as well as digital financial literacy and has paid attention to consumer protection by implementing laws and regulations in order to strengthen the effectiveness in protecting consumers rights and creating working groups in order to receive and handle complaints.

**Excellencies, Neak Oknhas, Distinguished Guests, Ladies and Gentlemen!**

The contribution from all stakeholders, such as ABC, is required to ensure a successful implementation of all above-mentioned activities. Taking this opportunity, I would like to extend my appreciation to ABC for its effort in improving financial literacy and consumer protection by supporting the implementation of projects on embedding financial literacy into the school curriculum, preparing discussion platforms and training programs, creating educational videos, preparing complaint handling mechanisms, launching the banking code of conduct, and enforcing the implementation of the Loan Contract and Standard Texts of Contractual Terms to strengthen Consumer Protection and Fair Competition in the Banking and Financial Sector. In addition, the MOU signing between ABC and the SOSORO museum in March with the support of the National Bank of Cambodia also reflects its contribution to enhancing financial literacy and understanding on Cambodia's economy and currency.

Nevertheless, I would like to request ABC to:

- Pay more attention to safeguard the common interests of member institutions,
- Be proactive in circulating news and responding to fake news that may affect the banking sector,
- Increase cooperation with the National Bank of Cambodia and other stakeholders in strengthening consumer protection and customer complaint handling,
- Strengthen compliance with laws and regulations, and the banking code of conducts to ensure financial stability and inclusive growth, and
- Strengthen capacity building for both ABC and its member institutions.

To conclude, I would like to once again extend my congratulations to ABC for their achievements over the past 30 years and also wish the board of directors, the management and ABC staff good health and success in all endeavors. I would like to wish your Excellencies, Neak Oknhas, Distinguished Guests, Ladies and Gentlemen with all the four gems of Buddha's blessings, namely longevity, nobility, happiness and strength.

**Thank you!**



# សុន្ទរកថាបើក
# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងពិធីបើកសិក្ខាសាលាផ្សព្វផ្សាយស្ដីពី
# "របាយការណ៍ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុឆ្នាំ២០២៣"

ថ្ងៃចន្ទ ១៣កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤



**សូមគោរព៖**

**- គណៈអធិបតី**

**- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានសេចក្ដីសោមនស្សជាអនេក ដែលបានចូលរួមក្នុងសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ ស្ដីពី "ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុឆ្នាំ២០២៣"។ នេះគឺជារបាយការណ៍ប្រចាំឆ្នាំលើកទី៦ហើយដែល ធនាគារជាតិនៃកម្ពុជា បានចេញផ្សាយ ដើម្បីរួមចំណែកលើកកម្ពស់ការយល់ដឹងពីស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា និងផ្ដល់ជាទស្សនវិស័យចំពោះស្ថិរភាពហិរញ្ញវត្ថុ។ ជាការពិត ការរួមចំណែករក្សាស្ថិរភាពហិរញ្ញវត្ថុបានក្លាយជាមុខងារ និងភារកិច្ចស្នូលថ្មីមួយទៀតរបស់ធនាគារកណ្ដាល ជាពិសេសចាប់តាំងពីវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ២០០៧-២០០៨ មក។ ក្នុងទិសដៅនេះ ធនាគារជាតិនៃកម្ពុជាក៏បានគិតគូរពីស្ថិរភាពហិរញ្ញវត្ថុ ដោយធ្វើការវិភាគ និងវាយតម្លៃលើសូចនាករសំខាន់ៗចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ២០១០ ដើម្បីពង្រឹងភាពធន់នៃប្រព័ន្ធហិរញ្ញវត្ថុជាតិ ដែលគ្របដណ្ដប់ដោយវិស័យធនាគារ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់មូលនិធិរូបិយវត្ថុជាតិ (IMF) ដែលបានផ្ដល់ជំនួយបច្ចេកទេសកសាងសមត្ថភាពសម្រាប់ការវិភាគស្ថិរភាពហិរញ្ញវត្ថុនៅកម្ពុជា។

ជាមួយការរីកចម្រើនឥតឈប់ឈរនៃប្រព័ន្ធធនាគារនិងសេដ្ឋកិច្ចកម្ពុជា និងភាពប្រទាក់ក្រឡាររវាងប្រព័ន្ធធនាគារនិងវិស័យផ្សេងទៀតកាន់តែមានភាពស្មុគស្មាញជាងមុន ការវិភាគស្ថិរភាពហិរញ្ញវត្ថុត្រូវបានកែលម្អឱ្យកាន់តែស៊ីជម្រៅ និងគ្រប់ជ្រុងជ្រោយជាបន្តបន្ទាប់។ ជាក់ស្ដែង នាឆ្នាំ២០១១ ធនាគារជាតិនៃកម្ពុជា បានបង្កើតគណៈកម្មាធិការស្ថិរភាពហិរញ្ញវត្ថុ និងក្រុមការងារដែលបានបន្ដផ្ដោតសំខាន់លើការតាមដាននិងវិភាគស្ថិរភាពប្រព័ន្ធធនាគារ។ បន្ទាប់មក ការិយាល័យទទួលបន្ទុកការវិភាគស្ថិរភាពហិរញ្ញវត្ថុត្រូវបានបង្កើត

នៅឆ្នាំ២០១៩។ នាពេលថ្មីៗនេះ គឺនៅចុងឆ្នាំ២០២៣កន្លងទៅ ការិយាល័យនេះត្រូវបានដំឡើងទៅជានាយកដ្ឋានស្ថិរភាពហិរញ្ញវត្ថុ ក្នុងគោលបំណងពង្រឹងគុណភាពនៃការវាយតម្លៃស្ថិរភាពហិរញ្ញវត្ថុ ដោយផ្តោតលើការតាមដាននិងការកាត់បន្ថយហានិភ័យជាប្រព័ន្ធ។ ការបង្កើតនាយកដ្ឋានថ្មីនេះ បង្ហាញពីការប្តេជ្ញារបស់ធនាគារជាតិនៃកម្ពុជាក្នុងការរួមចំណែករក្សាស្ថិរភាពហិរញ្ញវត្ថុជាតិថែមទៀត។



*វាគ្មិនបានឡើងធ្វើបទបង្ហាញពីខ្លឹមសារសង្ខេបនៃរបាយការណ៍ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុ ឆ្នាំ២០២៣*

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ខ្ញុំសូមរំលេចនូវចំណុចសំខាន់ៗមួយចំនួន នៃការវាយតម្លៃនៅក្នុងរបាយការណ៍ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុឆ្នាំ២០២៣ ដូចតទៅៈ

- ស្ថានភាពសេដ្ឋកិច្ចតំបន់និងពិភពលោកត្រូវបានវាយតម្លៃថាមានភាពធន់ បើទោះបីជាត្រូវប្រឈមនឹងការកើនឡើងនៃអត្រាការប្រាក់ និងកម្រិតខ្ពស់នៃអត្រាអតិផរណាសកលក៏ដោយ។ ក្នុងស្ថានភាពនេះ សេដ្ឋកិច្ចកម្ពុជាបន្តដើបឡើងក្នុងអត្រា ៥% ជាមួយនឹងកំណើនក្នុងល្បឿនខុសគ្នាតាមវិស័យ។ ទន្ទឹមនេះ អត្រាអតិផរណាបានថយចុះមកត្រឹម ២,១% ស្របតាមនិន្នាការអតិផរណាក្នុងតំបន់ និងការធ្លាក់ថ្លៃប្រេងនៅលើទីផ្សារអន្តរជាតិ។
- ការបង្កើនអត្រាការប្រាក់គោលនៅសហរដ្ឋអាមេរិក បានធ្វើឱ្យតម្លៃប្រាក់ដុល្លារអាមេរិកកើនថ្លៃធៀបនឹងរូបិយប័ណ្ណជាច្រើននៅលើទីផ្សារអន្តរជាតិ ប៉ុន្តែសម្ពាធមកលើប្រាក់រៀលត្រូវបានគ្រប់គ្រងដែលធ្វើឱ្យអត្រាប្តូរប្រាក់មានស្ថិរភាព តាមរយៈការផ្គត់ផ្គង់រូបិយវត្ថុក្នុងកម្រិតសមស្រប ការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ និងការប្រើប្រាស់ឧបករណ៍នយោបាយរូបិយវត្ថុផ្សេងៗ

ប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់។ ទន្ទឹមនេះ ទុនបម្រុងអន្តរជាតិរក្សាបានក្នុងកម្រិតសមស្រប ដែលអាចធានាការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់បាន ៧ខែ ខ្ពស់ជាងកម្រិតអប្បបរមា ៣ខែ ដែលប្រទេសកំពុងអភិវឌ្ឍន៍គួរមាន។ គួរបញ្ជាក់ផងដែរថា បំណុលក្រៅប្រទេសបានកើនឡើងបន្តិច ប៉ុន្តែសមាមាត្របំណុលធៀបនឹង ផ.ស.ស បានថយចុះ ដោយសារកំណើនសេដ្ឋកិច្ចមានកម្រិតខ្ពស់ជាងកំណើនបំណុលក្រៅប្រទេស។

- ប្រព័ន្ធធនាគារកម្ពុជាបន្តមានភាពរឹងមាំ ទោះបីជាទទួលរងសម្ពាធពីកត្តាខាងក្រៅដោយទ្រព្យសកម្ម និងប្រាក់បញ្ញើរបស់ប្រព័ន្ធធនាគារបានបន្តកើនឡើង។ ប៉ុន្តែ កំណើនទន់ខ្សោយនៃវិស័យមួយចំនួន និងការកើនឡើងនៃអត្រាការប្រាក់បានបណ្ដាលឱ្យតម្រូវការឥណទានថមថយ ទន្ទឹមនឹងការបង្កើនភាពប្រុងប្រយ័ត្នខ្ពស់របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុក្នុងការផ្ដល់ឥណទាន បានធ្វើឱ្យកំណើនឥណទានថយចុះមកនៅអត្រាមួយខ្ទង់ជាលើកដំបូងក្នុងរយៈពេលជាង ២ ទសវត្សរ៍ចុងក្រោយ។
- ទោះយ៉ាងណា កំណើនអត្រាការប្រាក់ក៏បានធ្វើឱ្យប្រាក់បញ្ញើកើនឡើងខ្ពស់រហូតដល់ ១៣% ក្នុងឆ្នាំ២០២៣។ នៅក្នុងប្រព័ន្ធធនាគារបច្ចុប្បន្ន ទ្រព្យសកម្មរបស់ធនាគារពាណិជ្ជមានចំនួនជាង ៩១% នៃទ្រព្យសកម្មសរុប បន្ទាប់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដ៏ធំមួយបានរួមបញ្ចូលជាមួយគ្រឹះស្ថានធនាគារមួយកាលពីឆ្នាំមុន ដែលនេះគឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការពង្រឹងភាពធន់របស់ប្រព័ន្ធធនាគារ។
- ការថយចុះកំណើនឥណទាន គួបផ្សំនឹងការបញ្ចប់ការរៀបចំឥណទានឡើងវិញបានបណ្ដាលឱ្យអនុបាតឥណទានមិនដំណើរការកើនឡើងលឿន តែស្ថិតក្នុងកម្រិតទាបនៅឡើយ។ ទោះយ៉ាងណា កំណើននេះតម្រូវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបង្កើនការតាមដាន និងវាយតម្លៃជាប្រចាំលើហានិភ័យមកលើស្ថិរភាពហិរញ្ញវត្ថុ។ ទន្ទឹមនេះ ការកើនឡើងនៃការធ្វើសំវិធានធន និងការចំណាយលើអត្រាការប្រាក់ បានធ្វើឱ្យប្រាក់ចំណេញក្នុងប្រព័ន្ធធនាគារថយចុះផងដែរ។ ជារួម ផ្អែកលើលទ្ធផលនៃការធ្វើស្ត្រេសតេស្ត ប្រព័ន្ធធនាគារកម្ពុជារក្សាបានភាពធន់ ស្របពេលដែលអនុបាតសាធនភាព និងសន្ទនីយភាពបន្តស្ថិតក្នុងកម្រិតខ្ពស់ បើទោះបីជាមានភាពខុសគ្នាខ្លះនៅកម្រិតគ្រឹះស្ថានក៏ដោយ។
- យ៉ាងណាមិញ យើងត្រូវតែបន្តមានភាពប្រុងប្រយ័ត្នខ្ពស់ ជាពិសេសចំពោះភាពទន់ខ្សោយនៃវិស័យអចលនទ្រព្យ ដែលមានការផ្គត់ផ្គង់លើសតម្រូវការ ហើយសន្ទស្សន៍ថ្លៃលំនៅឋាន នៅក្នុងឆមាសទី២ ឆ្នាំ២០២៣ បានថយចុះ ទន្ទឹមនឹងការថមថយលំហូរនៃវិនិយោគផ្ទាល់ពីបរទេសមកកាន់វិស័យនេះ។ ក្នុងស្ថានភាពនេះ ដើម្បីគ្រប់គ្រងហានិភ័យនៅក្នុងវិស័យអចលនទ្រព្យព្រមទាំងចៀសវាង និងកាត់បន្ថយផលប៉ះពាល់ដែលអាចកើតមានជាយថាហេតុមកលើស្ថិរភាព

ហិរញ្ញវត្ថុ អាជ្ញាធរពាក់ព័ន្ធទាំងអស់ នឹងត្រូវបន្តចូលរួមតាមដាននិងត្រួតពិនិត្យដោយហ្មត់ចត់ពីហានិភ័យក្នុងវិស័យ និងហានិភ័យប្រទាក់ក្រឡានៃវិស័យអចលនទ្រព្យ។

- ក្នុងរយៈពេល១ទសវត្សរ៍ចុងក្រោយនេះ វិស័យហិរញ្ញវត្ថុមិនមែនធនាគារបានបន្តរីកចម្រើនយ៉ាងឆាប់រហ័ស ដោយមូលធនូបនីយកម្មទីផ្សារមូលបត្រកម្មសិទ្ធិនិងមូលបត្របំណុល ក៏ដូចជាទ្រព្យសកម្មក្នុងវិស័យធានារ៉ាប់រងបានបន្តកើនឡើងជាលំដាប់។ មូលបត្របំណុលជាប្រាក់រៀលក៏ត្រូវបានបោះផ្សាយ ហើយបានរួមចំណែកគាំទ្រការប្រើប្រាស់រូបិយវត្ថុជាតិ និងចីរភាពបំណុល។
- ម៉្យាងទៀត ការប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិកបានកើនឡើងយ៉ាងឆាប់រហ័ស ជាពិសេសបន្ទាប់ពីវិបត្តិកូវីដ-១៩ ដោយក្នុងនោះប្រតិបត្តិការទូទាត់តាមរយៈប្រព័ន្ធបាគង និងខេអេចឃ្យូអរកូដបានកើនឡើងគួរឱ្យកត់សម្គាល់ ដែលបានរួមចំណែកសម្រួលពាណិជ្ជកម្ម ទេសចរណ៍ ការវិនិយោគ និងការផ្ទេរប្រាក់ពីក្រៅប្រទេស ព្រមទាំងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុផងដែរ។




ចំពោះទស្សនអនាគតលើស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុវិញ ខ្ញុំសូមលើកឡើងនូវចំណុចសំខាន់ៗមួយចំនួន រួមមាន៖

- សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងមានកំណើន ៦% នៅឆ្នាំ២០២៤នេះ ជាមួយនឹងកម្រិតអតិផរណាក្នុងរង្វង់ ២%។ កំណើនសេដ្ឋកិច្ចត្រូវបានគាំទ្រជាចម្បង ដោយការនាំចេញផលិតផលកាត់ដេរ និងមិនមែនកាត់ដេរ ការបន្តងើបឡើងនៃវិស័យទេសចរណ៍និងវិស័យពាក់ព័ន្ធ និងកំណើនរឹងមាំនៃវិស័យដឹកជញ្ជូន និងទូរគមនាគមន៍ ខណៈដែលវិស័យកសិកម្មអាចបន្តកើនឡើងយឺត។ លើសពីនេះ ការអនុវត្តកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី (FTAs) ត្រូវបានរំពឹងថានឹងរួមចំណែកទាក់ទាញ

លំហូរវិនិយោគ និងការនាំចេញទៅក្នុងតំបន់បន្ថែមទៀយ ដែលនឹងជួយជំរុញផលិតភាព និងការធ្វើពិពិធកម្មសេដ្ឋកិច្ច។

- ទោះយ៉ាងណា សេដ្ឋកិច្ចកម្ពុជាក៏ប្រឈមនឹងហានិភ័យមួយចំនួន ដូចជា ភាពតានតឹងនិងការបែងចែកផ្នែកភូមិសាស្ត្រនយោបាយ ការអូសបន្លាយនៃការរឹតបន្តឹងស្ថានភាពហិរញ្ញវត្ថុអន្តរជាតិ កំណើនយឺតជាងការរំពឹងទុកនៃសេដ្ឋកិច្ចចិន ការប្រែប្រួលអាកាសធាតុ និងការកើនឡើងនៃហានិភ័យសាយប័រ ជាដើម។ ហានិភ័យទាំងអស់នេះ អាចបណ្តាលឱ្យសកម្មភាពសេដ្ឋកិច្ច និងពាណិជ្ជកម្មពិភពលោកថយចុះ ដែលនឹងអាចប៉ះពាល់ផងដែរដល់ការនាំចេញ ការវិនិយោគ និងលំហូរមូលធនមកកម្ពុជា។ ក្នុងស្ថានភាពនេះ ប្រព័ន្ធធនាគារកម្ពុជាក៏ប្រឈមនឹងហានិភ័យផងដែរ ដូចជា ហានិភ័យឥណទាននិងទីផ្សារជាដើម។
- ប្រឈមនឹងហានិភ័យទាំងនេះ ធនាគារជាតិនៃកម្ពុជានឹងបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីធានានូវភាពរឹងមាំនៃប្រព័ន្ធហិរញ្ញវត្ថុកម្ពុជា ហើយនឹងដាក់ចេញវិធានការគាំទ្រតាមការចាំបាច់ សំដៅគាំទ្រកំណើនសេដ្ឋកិច្ចនិងរក្សាស្ថិរភាពហិរញ្ញវត្ថុជាតិ។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

អ្វីដែលខ្ញុំបានលើកឡើងគ្រាន់តែជាចំណុចសំខាន់ៗមួយចំនួនប៉ុណ្ណោះ នៅក្នុងរបាយការណ៍ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុឆ្នាំ២០២៣។ ខ្ញុំសូមអញ្ជើញអានរបាយការណ៍លម្អិត និងស្តាប់បទបង្ហាញព្រមទាំងចូលរួមក្នុងកិច្ចពិភាក្សានាពេលបន្តិចទៀតនេះ។ របាយការណ៍ទាំងស្រុង នឹងអាចទាញយកពីគេហទំព័ររបស់ធនាគារជាតិនៃកម្ពុជាចាប់ពីថ្ងៃនេះតទៅ។

ខ្ញុំសង្ឃឹមថារបាយការណ៍នេះនឹងក្លាយជាប្រភពព័ត៌មាន និងសម្រាប់ជំនួយដល់ការវិភាគនៃគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ខណៈដែលធនាគារជាតិនៃកម្ពុជានឹងបន្តលើកកម្ពស់ការវិភាគ កិច្ចសហការ និងការផ្សព្វផ្សាយជូនសាធារណជនពាក់ព័ន្ធនឹងស្ថិរភាពហិរញ្ញវត្ថុឱ្យបានស៊ីជម្រៅ និងទូលំទូលាយ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជួបប្រទះពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។ ខ្ញុំសូមដាក់ឱ្យប្រើប្រាស់របាយការណ៍ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុឆ្នាំ២០២៣ និងបើកសិក្ខាសាលាផ្សព្វផ្សាយចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**

# សុន្ទរកថា
# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ រវាង ធនាគារជាតិនៃកម្ពុជា និងក្រសួងកិច្ចការនារី ស្តីពី ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី

ថ្ងៃចន្ទ ៥រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៤




**សូមគោរព ៖**

- **លោកជំទាវកិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ ដែលជាតំណាងក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍ និងតំណាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលមានវត្តមាននៅទីនេះ**

ថ្ងៃនេះជាទិវាមួយដ៏មហោឡារិកប្រកបដោយសោមនស្ស ដែលធនាគារជាតិនៃកម្ពុជា ជាមួយក្រសួងកិច្ចការនារី បានព្រមព្រៀងក្នុងការចុះអនុស្សរណៈយោគយល់ ស្តីពី ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី ដែលមានរយៈពេល ៥ឆ្នាំ។ អនុស្សរណៈនៃការយោគយល់នេះ មានគោលបំណងបង្កើតក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការក្នុងការបន្តលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ សម្រាប់ស្ត្រី និងសហគ្រិនស្ត្រី តាមរយៈការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុនិងហិរញ្ញវត្ថុឌីជីថល ការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដោយលើកកម្ពស់ផ្នត់គំនិតវិជ្ជមាន និងការពង្រីកភាពជាដៃគូក្នុងការជំរុញបរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី និងសហគ្រិនស្ត្រី។ ការណ៍នេះនឹងចូលរួមជំរុញបន្ថែមដល់ស្ត្រី និងសហគ្រិន

ស្ត្រី ក្នុងការទទួលបាន និងប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ ព្រមទាំងការទាញយកប្រយោជន៍ពីការប្រើប្រាស់ឌីជីថលប្រកបដោយភាពទាន់សម័យ ឆ្លាតវៃ និងការទទួលខុសត្រូវ និងការបង្ការហានិភ័យដែលអាចកើតឡើង។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា ដែលបានចូលរួមក្នុងកម្មវិធីនាព្រឹកនេះ និងសូមថ្លែងអំណរគុណដល់ក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ដែលចូលរួមសហការជាមួយធនាគារជាតិនៃកម្ពុជា ក្នុងការផ្តួចផ្តើមកម្មវិធីនានា ជាពិសេស ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី និងសហគ្រិនស្ត្រី នាពេលកន្លងមក។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយស ជាទីមេត្រី!**

បរិយាបន្នហិរញ្ញវត្ថុដើរតួនាទីយ៉ាងសំខាន់ ក្នុងការជំរុញកំណើនសេដ្ឋកិច្ច កាត់បន្ថយវិសមភាព និងភាពក្រីក្រនៅកម្ពុជា ជាពិសេស សម្រាប់ស្ត្រីដែលមានចំណូលទាប និងនៅទីជនបទ។ ជាមួយគ្នានេះ ការចូលរួមរបស់ស្ត្រីក្នុងសកម្មភាពសេដ្ឋកិច្ច និងសង្គម តាមរយៈការទទួលបាន និងប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ មិនត្រឹមតែជួយជំរុញអាជីវកម្មផ្ទាល់ខ្លួន ថែមទាំងអាចចូលរួមក្នុងការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព រួមមាន៖ ការបង្កើនឱកាសការងារ ការកាត់បន្ថយភាពក្រីក្រ ការជំរុញសមភាពយេនឌ័រ និងការលើកកម្ពស់ការអប់រំនិងសុខមាលភាព ព្រមទាំងការចូលរួមកាត់បន្ថយសកម្មភាពដែលប៉ះពាល់ដល់បរិស្ថាន និងបម្រែបម្រួលអាកាសធាតុ ជាដើម។ ក្នុងន័យនេះរាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវយុទ្ធសាស្ត្រជាតិ ស្តីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ ក្នុងគោលដៅកាត់បន្ថយអត្រាស្ត្រីដែលមិនទាន់ទទួលបានសេវាហិរញ្ញវត្ថុឱ្យបានពាក់កណ្តាលពី ២៧% មក ១៣%



និងពង្រីកការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ ពី ៥៩% ទៅ ៧០% ត្រឹមឆ្នាំ២០២៥។ ដើម្បីចូលរួមគាំទ្រយុទ្ធសាស្ត្រជាតិរបស់រដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជា បានសហការជាមួយក្រសួង-ស្ថាប័នជាតិនិងអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា ដើម្បីលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ បង្កើនសិទ្ធិក្នុងការប្រើប្រាស់សេវាហិរញ្ញវត្ថុ និងពង្រឹងកិច្ចការពារអតិថិជនដោយផ្តោតសំខាន់លើកុមារ ស្ត្រី សហគ្រិនស្ត្រី និងប្រជាពលរដ្ឋនៅតាមតំបន់មូលដ្ឋាន ជាដើម។

ខ្ញុំសូមបញ្ជាក់ផងដែរថា កាលពីឆ្នាំ២០១៩ ធនាគារជាតិនៃកម្ពុជា បានចុះអនុស្សរណៈនៃការយោគយល់ ជាមួយក្រសួងកិច្ចការនារី ស្តីពី "ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រីនិងស្ត្រីក្នុងសហគ្រិនភាព" ដែលមានរយៈពេលមួយឆ្នាំ។ ក្រោមកិច្ចសហការនេះ សមិទ្ធផលដែលទទួលបានរួមមាន៖ ១/-ការបណ្តុះបណ្តាលគ្រូបង្គោល ស្តីពី ចំណេះដឹងផ្នែកហិរញ្ញវត្ថុដល់សិក្ខាកាមមកពីក្រសួងកិច្ចការនារី មន្ទីរកិច្ចការនារីគោលដៅ និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីនៅក្នុងខេត្តគោលដៅចំនួន ៤ គឺ ខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ដោយមានអ្នកចូលរួមប្រមាណ ៣០រូប ក្នុងវគ្គនីមួយៗ ២/-ការបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ ចំនួន ៤លើក និងវេទិកាជជែកពិភាក្សានៃសហគ្រិនស្ត្រីតាមប្រព័ន្ធអនឡាញ ចំនួន ៣លើក សម្រាប់ស្ត្រី សហគ្រិនស្ត្រីនិងសិស្សនិស្សិតជាស្ត្រី ៣/-ការបណ្តុះបណ្តាលស្តីពីចំណេះដឹងផ្នែកហិរញ្ញវត្ថុនិងហិរញ្ញវត្ថុឌីជីថលសម្រាប់សហគ្រិនស្ត្រី ក្រោមកិច្ចគាំទ្ររបស់អង្គការ UNESCAP នៅក្នុងខេត្តចំនួន ៣ គឺ ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តបាត់ដំបង ដោយមានអ្នកចូលរួមប្រមាណ ១០០នាក់ ក្នុងខេត្តនីមួយៗ និង ៤/-ការចូលរួមជាវាគ្មិន និងគ្រូឧទ្ទេសនាមក្នុងសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលលើការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុរបស់ស្ត្រី សហគ្រិនភាពស្ត្រី និងសិស្សនិស្សិតជាស្ត្រី ដែលរៀបចំដោយក្រសួងកិច្ចការនារី ជាដើម។ បើទោះបីជាការអនុវត្តត្រូវបានអូសបន្លាយពេលវេលាដែលមិនស្របតាមការកំណត់ក៏ដោយ អនុស្សរណៈនៃការយោគយល់នេះត្រូវបានបញ្ចប់ប្រកបដោយភាពជោគជ័យក្នុងខែមីនា ឆ្នាំ២០២២។

ជាមួយគ្នានេះ កម្រិតបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា មានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ដែលឆ្លុះបញ្ចាំងតាមរយៈលទ្ធផលទទួលបានពីការស្រាវជ្រាវ Mobile Tracker Survey របស់មូលនិធិ UNCDF ដោយបានបង្ហាញថា អត្រាអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការមានការកើនឡើងពី ៥៩% (ឆ្នាំ២០១៥) មកដល់ ៦៧% (ឆ្នាំ២០២១) ដែលខិតជិតនឹងគោលដៅ ៧០% ត្រឹមឆ្នាំ២០២៥។ បើទោះបីជាយ៉ាងនេះក្តី អត្រាការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការ

របស់ស្ត្រី នៅមានភាពទ្រឹងដែលទាមទារការខិតខំប្រឹងប្រែង ការយកចិត្តទុកដាក់ និងកិច្ចសហការជាមួយភាគីពាក់ព័ន្ធជាបន្តទៀត ដើម្បីសម្រេចបាននូវគោលដៅដែលបានកំណត់។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយស ជាទីមេត្រី!**

ការចុះអនុស្សរណៈនៃការយោគយល់នាថ្ងៃនេះ ជាសក្ខីភាពដែលបានបង្ហាញពីវឌ្ឍនភាព នៃកិច្ចសហការរវាងធនាគារជាតិនៃកម្ពុជា និងក្រសួងកិច្ចការនារីក្នុងភាពជាដៃគូ ដើម្បីបន្តលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី ប្រកបដោយប្រសិទ្ធភាព ប៉ុន្តែបេសកកម្មនេះទាមទារការចូលរួមសហការពីភាគីពាក់ព័ន្ធបន្ថែមទៀត។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមលើកទឹកចិត្តឱ្យគ្រប់ភាគីពាក់ព័ន្ធចូលរួមបន្តសហការក្នុងសកម្មភាពដែលស្ថាប័ននីមួយៗបាននិងកំពុងអនុវត្ត និងបង្កើនអាទិភាពទៅលើការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី ដើម្បីឱ្យសម្រេចបាននូវគោលដៅដែលបានកំណត់។ ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ និងក្រុមការងារក្រសួងកិច្ចការនារី ព្រមទាំងដៃគូអភិវឌ្ឍ ដែលចូលរួមសហការជាមួយធនាគារជាតិនៃកម្ពុជា ក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី និងសហគ្រិនស្ត្រី នាពេលកន្លងមក និងសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងភ្ញៀវកិត្តិយសទាំងអស់ សូមមានសុខភាពល្អ និងសម្រេចជោគជ័យគ្រប់ភារកិច្ច។

**សូមអរគុណ!**



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## សេចក្តីប្រកាសព័ត៌មានរួម
## ស្តីពី
## ការទទួលបានពានរង្វាន់សកលថ្នាក់ក្រសួង (Global Summit of Women 2024 Roundtable Ministerial Award) លើ «គម្រោងដែលមានផលជះវិជ្ជមានចំពោះស្ត្រី និងក្មេងស្រី» តាមរយៈការប្រើប្រាស់ប្រព័ន្ធទូទាត់ "បាគង" ក្នុងកិច្ចប្រជុំកំពូលស្ត្រីពិភពលោក ឆ្នាំ២០២៤ ទីក្រុងម៉ាឌ្រីដ ប្រទេសអេស្ប៉ាញ

នៅថ្ងៃសុក្រ ៣កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ ក្រសួងកិច្ចការនារី និង ធនាគារជាតិនៃកម្ពុជា បានទទួលពានរង្វាន់សកលថ្នាក់ក្រសួង (Global Summit of Women 2024 Roundtable Ministerial Award) លើ **«គម្រោងដែលមានផលជះវិជ្ជមានចំពោះស្ត្រី និងក្មេងស្រី»** តាមរយៈការប្រើប្រាស់ប្រព័ន្ធទូទាត់ **«បាគង»** ពីកិច្ចប្រជុំកំពូលស្ត្រីពិភពលោក ឆ្នាំ២០២៤ ដែលត្រូវបានរៀបចំឡើងនៅទីក្រុងម៉ាឌ្រីដ ប្រទេសអេស្ប៉ាញ។

គណៈប្រតិភូកម្ពុជា ដឹកនាំដោយ លោកជំទាវកិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី បាននាំយកគម្រោងបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី តាមរយៈការប្រើប្រាស់ប្រព័ន្ធទូទាត់ «បាគង» អភិវឌ្ឍ ដោយធនាគារជាតិនៃកម្ពុជា បង្ហាញជូនដល់អង្គប្រជុំ នៅក្នុងវេទិកាតុមូលថ្នាក់រដ្ឋមន្ត្រី នៃកិច្ចប្រជុំកំពូលស្ត្រីពិភពលោក ឆ្នាំ២០២៤។

ក្រោយពីវាយតម្លៃ និងពិនិត្យយ៉ាងល្អិតល្អន់ដោយគណៈកម្មការនៃកិច្ចប្រជុំកំពូលស្ត្រីពិភពលោករួចមក គម្រោងបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី តាមរយៈប្រព័ន្ធទូទាត់បាគង ត្រូវបានចាត់ទុកថាជាគម្រោងដែលបានផ្តល់អត្ថប្រយោជន៍ និងរួមចំណែកដ៏សំខាន់ ក្នុងការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និងសហគ្រិនស្ត្រី ជាពិសេសស្ត្រីដែលរស់នៅតាមតំបន់ជនបទ ហើយត្រូវបានគណៈកម្មការបានសម្រេចផ្តល់ពានរង្វាន់សកលថ្នាក់ក្រសួង លើ «គម្រោងដែលមានផលជះវិជ្ជមានចំពោះស្ត្រី និងក្មេងស្រី» ដល់ស្ថាប័នទាំងពីរ។

គម្រោងនេះបានរួមចំណែកយ៉ាងសំខាន់ ក្នុងក្របខណ្ឌនៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល សំដៅឆ្ពោះទៅសម្រេចឱ្យបានសេដ្ឋកិច្ចឌីជីថល សង្គមឌីជីថល និងប្រជាពលរដ្ឋឌីជីថល តាមរយៈការអភិវឌ្ឍមូលធនមនុស្សផ្នែកឌីជីថល និងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ដោយបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី លើកកម្ពស់អក្ខរកម្មហិរញ្ញវត្ថុឌីជីថល និងធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ស្ត្រី ព្រមទាំងក្រុមគ្រួសារ តាមរយៈ ១). ការផ្តល់ឯករាជ្យភាពផ្នែកហិរញ្ញវត្ថុ និងជួយពួកគេឱ្យកាន់តែមានសមត្ថភាព និងលទ្ធភាពគ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួន ២). ការជួយសហគ្រិនស្ត្រីឱ្យទទួលបានសេវាទូទាត់តាមប្រព័ន្ធឌីជីថល ដែលមានភាពងាយស្រួល រហ័ស និងមានសុវត្ថិភាពខ្ពស់ និង ៣). ការគាំទ្រស្ត្រីឱ្យទទួលបានសេវាហិរញ្ញវត្ថុផ្លូវការផ្សេងៗ ដូចជាសេវាឥណទាន និងសេវាប្រាក់បញ្ញើ ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការចាប់ផ្តើម ឬពង្រីកអាជីវកម្ម ក៏ដូចជាវិនិយោគក្នុងការអប់រំ ឬ ត្រៀមទុកសម្រាប់គ្រាអាសន្ន៕ Sy MS

ថ្ងៃសុក្រ ៣កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០២៤

# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អញ្ជើញចុះហត្ថលេខាលើអនុស្សរណៈយោគយល់ទ្វេភាគី ស្តីពី "កិច្ចសហប្រតិបត្តិការទូទាត់ឆ្លងដែនតាមយូរអរកូត" នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ




នៅថ្ងៃព្រហស្បតិ៍ ៩កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញចុះហត្ថលេខាលើអនុស្សរណៈយោគយល់ទ្វេភាគីចំនួន ៣ ដាច់ដោយឡែកពីគ្នា ស្តីពី "កិច្ចសហប្រតិបត្តិការទូទាត់ឆ្លងដែនតាមយូរអរកូត" នៅក្នុងរបៀបវារៈនៃវេទិកាធុរកិច្ចកម្ពុជា-កូរ៉េ នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ។ ក្នុងនោះ អនុស្សរណៈទី១ ធ្វើឡើងជាមួយធនាគារគូកមីន (Kookmin Bank Co., Ltd.) ទី២ ជាមួយស្ថាប័ន JB Financial Group Co., Ltd. និងទី៣ ជាមួយធនាគារអ៊ូរី (Woori Bank)។ នាឱកាសនោះ ក្រុមហ៊ុនក្រេឌីតប្យូរ៉ូ (ខេមបូឌា) ក៏បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ត្រីភាគីជាមួយក្រុមហ៊ុនក្រេឌីតប្យូរ៉ូ (កូរ៉េ) និងធនាគារ JEONBUK ស្តីពី "កិច្ចសហការចែករំលែកព័ត៌មានឥណទានឆ្លងដែន" រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ។ ពិធីចុះហត្ថលេខានេះរៀបចំឡើង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងដំណើរទស្សនកិច្ចផ្លូវការរបស់ សម្តេចធិបតី នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ពីថ្ងៃទី១៥-១៨ ខែឧសភា ឆ្នាំ២០២៤។ អនុស្សរណៈយោគយល់នេះនឹងជួយសម្រួលដល់សកម្មភាពពាណិជ្ជកម្ម វិស័យទេសចរណ៍ លើកកម្ពស់ប្រតិបត្តិការទូទាត់ឆ្លងដែន ការផ្ទេរប្រាក់ និងការទូទាត់ប្រាក់ដោយប្រើរូបិយវត្ថុជាតិ

សំដៅបង្កើនទំនុកចិត្ត សុវត្ថិភាព ប្រសិទ្ធភាព ស្ថិរភាព និងបរិយាបន្នបន្ថែមទៀត ដែលជាប្រយោជន៍សម្រាប់ប្រជាពលរដ្ឋ និងធុរជនរបស់ប្រទេសទាំងពីរ ព្រមទាំងនឹងចូលរួមចំណែកពង្រឹងការផ្លាស់ប្តូរព័ត៌មានឥណទានកាន់តែមានប្រសិទ្ធភាព និងសុវត្ថិភាព។











# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អញ្ជើញជាអធិបតីក្នុងពិធីប្រកាសដាក់ឱ្យដំណើរការគម្រោងថ្នាលច្រករបៀងតម្លាភាពហិរញ្ញវត្ថុ រវាងកម្ពុជា និងសិង្ហបុរី




នៅថ្ងៃអង្គារ ១២កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និង**ឯកឧត្តម** Leong Sing Chiong នាយករងគ្រប់គ្រង អាជ្ញាធររូបិយវត្ថុសិង្ហបុរី អញ្ជើញចូលរួមក្នុងពិធីប្រកាសដាក់ឱ្យដំណើរការ គម្រោងថ្នាលច្រករបៀងតម្លាភាពហិរញ្ញវត្ថុ (Financial Transparency Corridor-FTC) រវាងកម្ពុជា និងសិង្ហបុរី នៅវិមានរដ្ឋាភិបាល ISTANA នៃប្រទេសសិង្ហបុរី។ ព្រឹត្តិការណ៍ដាក់ឱ្យដំណើរការគម្រោងថ្នាល FTC នេះ ត្រូវបានរៀបចំឡើងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **ឯកឧត្តម ឡរ៉េន វ៉ុង** នាយករដ្ឋមន្ត្រី សាធារណរដ្ឋសិង្ហបុរី ក្នុងដំណើរបំពេញទស្សនកិច្ចផ្លូវការរបស់ សម្តេចធិបតី ទៅកាន់សាធារណរដ្ឋសិង្ហបុរី ពីថ្ងៃទី១៨ ដល់ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤។ គម្រោងថ្នាល FTC នេះជាហេដ្ឋារចនាសម្ព័ន្ធឌីជីថលសម្រាប់បង្កើតកិច្ចព្រមព្រៀងជាមុន រវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជានិងសិង្ហបុរី ដើម្បីមានលទ្ធភាពប្រើប្រាស់ទិន្នន័យសហគ្រាសធុនតូច និងមធ្យមនៅប្រទេសទាំងពីរ ក្នុងការវាយតម្លៃឥណទានឱ្យបានប្រសើរជាងមុន សំដៅជំរុញសកម្មភាពពាណិជ្ជកម្ម និងប្រើប្រាស់សេវាហិរញ្ញវត្ថុឆ្លងដែនទ្វេភាគី។

# ឯកឧត្តម ជា ចាន់តូ ទេសាភិបាលកិត្តិយស

## ធនាគារជាតិនៃកម្ពុជា អញ្ជើញជាអធិបតីក្នុងពិធីទទួលទេវតាឆ្នាំថ្មី ព្រះនាមមហោទរាទេវី ព្រមទាំងសូត្រមន្តចម្រើនព្រះបរិត្តពុទ្ធជ័យមង្គល និងរាប់បាត្រព្រះសង្ឃ

នាព្រឹកថ្ងៃអង្គារ ១កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៤ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ដែលនឹងឈានចូលមកដល់នាពេលខាងមុខនេះ ធនាគារជាតិនៃកម្ពុជា បានរៀបចំពិធីទទួលទេវតាឆ្នាំថ្មី ព្រះនាមមហោទរាទេវី ព្រមទាំងសូត្រមន្តចម្រើនព្រះបរិត្តពុទ្ធជ័យមង្គល និងរាប់បាត្រព្រះសង្ឃចំនួន ១២០អង្គ ក្រោមអធិបតីភាព **ឯកឧត្តម ជា ចាន់តូ** ទេសាភិបាលកិត្តិយស ធនាគារជាតិនៃកម្ពុជា និងលោកជំទាវ ព្រមទាំងមានការចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់ ក៏ដូចជាមន្ត្រី-បុគ្គលិកទាំងអស់ នៅធនាគារជាតិនៃកម្ពុជា អគារសែនសុខ។













# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អញ្ជើញជាអធិបតីចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីពី "កិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រសម្រាប់ហិរញ្ញប្បទានឌីជីថលបៃតងនៅកម្ពុជា"



*លោកសាស្ត្រាចារ្យ Tetsuya Watanabe ប្រធានវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាន និងអាស៊ីបូព៌ា (ERIA)*



*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា*




នាថ្ងៃសុក្រ ៣រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និង**លោកសាស្ត្រាចារ្យ** Tetsuya Watanabe ប្រធានវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាន និងអាស៊ីបូព៌ា (ERIA) អញ្ជើញជាអធិបតី និងចុះហត្ថលេខាលើអនុស្សរណៈ-យោគយល់ ស្តីពី "កិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រសម្រាប់ហិរញ្ញប្បទានឌីជីថលបៃតងនៅកម្ពុជា" នៅរាជធានីភ្នំពេញ។ ក្របខ័ណ្ឌនៃកិច្ចសហ-ប្រតិបត្តិការនេះ នឹងជួយកសាងសមត្ថភាពរបស់ភាគីពាក់ព័ន្ធ តាមរយៈការរៀបចំសិក្ខាសាលា ដើម្បីពិភាក្សាក៏ដូចជា ពិគ្រោះយោបល់ទាក់ទងនឹងបរិវត្តកម្មបៃតង និងនវានុវត្តន៍ឌីជីថល និងស្វែងរកឱកាសក្នុងដំណើរអភិវឌ្ឍន៍គោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) និងហិរញ្ញប្បទានឌីជីថលបៃតងនៅប្រទេស

កម្ពុជា។ ជាងនេះទៀត អនុស្សរណៈយោគយល់នេះក៏អនុញ្ញាតឱ្យមានការអនុវត្តគម្រោងស្រាវជ្រាវរួមគ្នាជុំវិញទិដ្ឋភាពហិរញ្ញប្បទានឌីជីថលបៃតងផងដែរ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការលើកកម្ពស់គម្រោងអភិវឌ្ឍន៍ប្រកបដោយចីរភាព ដូចមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល។ ធនាគារជាតិនៃកម្ពុជា នាពេលកន្លងមកបានចូលរួមក្នុងក្របខ័ណ្ឌអន្តរជាតិ តាមរយៈគំនិតផ្តួចផ្តើម និងកិច្ចពិភាក្សា ជាមួយស្ថាប័នមួយចំនួនដូចជា ក្រុមការងារបរិយាបន្នហិរញ្ញវត្ថុបៃតង (IGFWG) បណ្តាញសម្រាប់ប្រព័ន្ធហិរញ្ញវត្ថុបៃតង (NGFS) ក្រុមការងារអាស៊ានលើកិច្ចការបណ្តាញធនាគារនិងហិរញ្ញវត្ថុប្រកបដោយចីរភាព (ASEAN Taskforce on Sustainable Finance) អង្គការ UNESCAP សម្ព័ន្ធសម្រាប់បរិយាបន្នហិរញ្ញវត្ថុ (AFI) និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ជាដើម ក្នុងកិច្ចការពង្រឹងការចូលរួមផ្តល់ហិរញ្ញប្បទានបៃតង។ ធនាគារជាតិនៃកម្ពុជា ក៏បានវិនិយោគទុនបម្រុងអន្តរជាតិមួយផ្នែកលើសញ្ញាបណ្ណបៃតង ព្រមទាំងបានក្លាយជាសមាជិកនៃគណៈកម្មការពិគ្រោះយោបល់សម្រាប់មូលនិធិបៃតងក្នុងតំបន់អាស៊ីអាគ្នេយ៍ក្នុងឆ្នាំ២០២២ ផងដែរ។









# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមក្នុងកិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលនៃប្រទេសនិយាយភាសាបារាំង



នៅថ្ងៃព្រហស្បតិ៍-សុក្រ ៨-៩រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣០-៣១ ខែឧសភា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមក្នុងកិច្ចប្រជុំថ្នាក់ទេសាភិបាល ធនាគារគារកណ្តាលនៃប្រទេសនិយាយភាសាបារាំង (ហ្វ្រង់កូហ្វូន) លើកទី៣០ នៅទីក្រុងព្រុចសែល ប្រទេសបែលហ្ស៊ិក។ កិច្ចប្រជុំហ្វ្រង់កូហ្វូនក្នុងឆ្នាំ២០២៤នេះ មានវត្តមានចូលរួមពីថ្នាក់ទេសាភិបាល ធនាគារកណ្តាលចំនួន ២០ នៃប្រទេសចំនួន ៤០ នៅទ្វីបអឺរ៉ុប អាមេរិក អាហ្វ្រិក និងអាស៊ី។ អង្គប្រជុំបានពិភាក្សាលើប្រធានបទមួយចំនួនដូចជា ១/- ការអនុវត្តនយោបាយរូបិយវត្ថុក្នុងស្ថានភាពមិនប្រាកដប្រជា និងមានហានិភ័យក៏ដូចជាដំណើរវិវដ្តថ្មីៗ ២/- ការទប់ទល់នឹងការផ្លាស់ប្តូរអាកាសធាតុ ៣/- ការបែងចែកភូមិសាស្ត្រនយោបាយ ៤/- ការពង្រឹងសុវត្ថិភាពសាយប័រ និង ៥/- ឯករាជ្យភាពរបស់ធនាគារកណ្តាល។ ក្នុងឱកាសនោះ លោកជំទាវក៏បានចូលរួមចែករំលែកបទពិសោធន៍របស់កម្ពុជាក្នុងការរួមចំណែកក្នុងការទប់ទល់នឹងការប្រែប្រួលអាកាសធាតុ តាមរយៈការចូលរួមក្នុងបណ្តាញថ្នាក់តំបន់ និងអន្តរជាតិពាក់ព័ន្ធនឹងហិរញ្ញវត្ថុបៃតង ការអនុវត្តគោលការណ៍គាំទ្រការផ្តល់ហិរញ្ញវត្ថុ



ប្រកបដោយចីរភាពនៅក្នុងប្រព័ន្ធធនាគារ ព្រមទាំងការវិនិយោគទុនបម្រុងអន្តរជាតិលើសញ្ញាបណ្ណបៃតងជាដើម។ លើសពីនេះ លោកជំទាវក៏បានលើកមតិយោបល់ ក្នុងការជំរុញឱ្យមានការចូលរួមបន្ថែមទៀតរបស់មូលនិធិនិងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ក៏ដូចជាប្រទេសអភិវឌ្ឍន៍ ក្នុងន័យគាំទ្រផ្តល់ហិរញ្ញប្បទានបៃតង ព្រមទាំងពង្រឹងកិច្ចសហការនិងសាមគ្គីភាពលើការគាំទ្រគម្រោងវិនិយោគបៃតង ដោយការទិញសញ្ញាបណ្ណបៃតងទៅវិញទៅមកជាដើម។ គួររំលេចផងដែរថា កិច្ចប្រជុំហ្វ្រង់កូហ្វូនត្រូវបានរៀបចំឡើងរៀងរាល់ពីរឆ្នាំម្តង ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការរវាងប្រទេសជាសមាជិកហ្វ្រង់កូហ្វូន និងផ្លាស់ប្តូរយោបល់ ក៏ដូចជាបទពិសោធន៍លើប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងធនាគារកណ្តាល។









# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា និងលោកជំទាវ Natela Turnava ដឹកនាំគណៈប្រតិភូ ចូលរួមកិច្ចប្រជុំទ្វេភាគីរវាង ធនាគារជាតិនៃកម្ពុជា និងធនាគារជាតិនៃហ្សកហ្ស៊ី




នាថ្ងៃសុក្រ ១០រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និង**លោកជំទាវ** Natela Turnava ទេសាភិបាលស្តីទី ធនាគារជាតិនៃហ្សកហ្ស៊ី បានដឹកនាំគណៈប្រតិភូ ចូលរួមកិច្ចប្រជុំទ្វេភាគី នៅទីក្រុងប៊ីលីស៊ី ប្រទេសហ្សកហ្ស៊ី។ នេះជាលើកដំបូងដែលធនាគារកណ្តាលទាំងពីរបានចាប់ផ្តើមពង្រឹងកិច្ចសហប្រតិបត្តិការ ដោយបានចុះអនុស្សរណៈ-យោគយល់ ក្នុងគោលបំណងបង្កើតក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ ក្នុងនោះរួមមានការចែករំលែកចំណេះដឹងនិងបទពិសោធន៍ក្នុងការងារបច្ចេកទេសរបស់ធនាគារកណ្តាល។ ថ្នាក់ដឹកនាំទាំងពីរបានពិភាក្សាផ្លាស់ប្តូរទស្សនៈលើស្ថានភាពសេដ្ឋកិច្ច ដំណើរការអភិវឌ្ឍន៍ក្នុងវិស័យធនាគារ នយោបាយរូបិយវត្ថុនិងស្ថិរភាពហិរញ្ញវត្ថុ ចីរភាពហិរញ្ញវត្ថុ ព្រមទាំងបានកំណត់ទិសដៅកិច្ចសហប្រតិបត្តិការទ្វេភាគីនាពេលអនាគត។ ឆ្លងតាមកិច្ចពិភាក្សា ធនាគារជាតិនៃហ្សកហ្ស៊ី បានទទួលជោគជ័យក្នុងការកាត់បន្ថយដុល្លារូបនីយកម្មប្រកបដោយជោគជ័យក្នុងរយៈពេលជាង ១០ឆ្នាំនេះ ដែលបទពិសោធន៍នេះនឹងជួយជាធាតុចូលដល់ធនាគារជាតិនៃកម្ពុជាក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយបន្ថែមទៀតនាពេលខាងមុខ។ ស្របពេលជាមួយគ្នានេះ

ភាគីធនាគារជាតិនៃហ្សកហ្ស៊ីបានស្នើធនាគារជាតិនៃកម្ពុជាចែករំលែកបទពិសោធន៍លើការអភិវឌ្ឍប្រព័ន្ធទូទាត់ តាមរយៈការបង្កើតប្រព័ន្ធស្តង់ដារឃ្យូអរកូត និងការទូទាត់ឆ្លងដែនជាដើម។ ភាគីទាំងពីរប្តេជ្ញាពង្រឹងកិច្ចសហប្រតិបត្តិការ ព្រមទាំងរៀនសូត្រពីគ្នាទៅវិញទៅមកបន្តទៀត។ គួររំលេចថា ប្រទេសហ្សកហ្ស៊ីគឺជាប្រទេសមួយស្ថិតនៅតំបន់កូកាស៊ីសពោលគឺនៅចំណុចប្រសព្វនៃតំបន់អឺរ៉ុបខាងកើត និងអាស៊ីខាងលិច។





# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមជាវាគ្មិនកិត្តិយសក្នុងវេទិកាពិភាក្សា ក្រោមប្រធានបទ "មូលធនប្រកបដោយចីរភាព៖ ហិរញ្ញវត្ថុដែលគិតគូរពីបរិស្ថាន"




នៅថ្ងៃចន្ទ ១៣រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមជាវាគ្មិនកិត្តិយសក្នុងវេទិកាពិភាក្សាក្រោមប្រធានបទ "មូលធនប្រកបដោយចីរភាព៖ ហិរញ្ញវត្ថុដែលគិតគូរពីបរិស្ថាន" នៅទីក្រុងឌុយបៃ នៃប្រទេសអេមីរ៉ាតអារ៉ាប់រួម។

វេទិកាពិភាក្សានេះត្រូវបានរៀបចំជាកម្មវិធីពិសេសមួយនៃកិច្ចប្រជុំកំពូលបច្ចេកវិទ្យាហិរញ្ញវត្ថុឌុយបៃ (Dubai Fintech Summit) ក្នុងគោលបំណងពិភាក្សានិងចែករំលែកទស្សនៈទាក់ទងនឹងតួនាទីរបស់ធនាគារកណ្តាល និងបច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងការចូលរួមលើកកម្ពស់បរិស្ថានបៃតង។ លោកជំទាវទេសាភិបាលបានជម្រាបជូនអង្គវេទិកា អំពីតួនាទីដ៏សំខាន់នៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងការជំរុញនិរន្តរភាពហិរញ្ញវត្ថុ ព្រមទាំងការអភិវឌ្ឍប្រព័ន្ធទូទាត់នៅកម្ពុជា ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល និងកាត់បន្ថយការចំណាយក្នុងការផ្ទេរប្រាក់របស់ប្រជាជន។ លើសពីនេះ លោកជំទាវបានចែករំលែកបទពិសោធន៍នៃការវិនិយោគទុនបម្រុងអន្តរជាតិរបស់ ធនាគារជាតិនៃកម្ពុជា លើសញ្ញាប័ណ្ណបៃតង និងសញ្ញាប័ណ្ណដែលពាក់ព័ន្ធនឹងបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ដែលត្រូវបានបោះផ្សាយដោយ






ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ សំដៅរួមចំណែកក្នុងការលើកកម្ពស់បរិស្ថាន។ គួររំលេចថា កិច្ចប្រជុំកំពូលបច្ចេកវិទ្យាហិរញ្ញវត្ថុឌុយបៃ បានប្រព្រឹត្តិទៅរយៈពេលពីរថ្ងៃ គឺថ្ងៃទី៦-៧ ខែឧសភា ឆ្នាំ២០២៤ ដោយមានអ្នកចូលរួមប្រមាណ ១.០០០ រូប ជាអ្នកតាក់តែងគោលនយោបាយវិនិយោគិន សាស្ត្រាចារ្យអ្នកស្រាវជ្រាវ និងអ្នកសារព័ត៌មាន ដែលមកពីប្រទេសជាង ១០០ ទូទាំងពិភពលោក។

# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមជាវាគ្មិនក្នុងកិច្ចពិភាក្សានៃវេទិកា Nikkei Forum លើកទី២៩ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន



នៅថ្ងៃសុក្រ ២រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមជាវាគ្មិនក្នុងកិច្ចពិភាក្សាលើប្រធានបទ ស្តីពី "តើតំបន់អាស៊ីអាចសម្រេចបាននូវគោលដៅសូន្យ នៃការបំភាយឧស្ម័នផ្ទះកញ្ចក់សុទ្ធដែរឬទេ?" ដែលជាកម្មវិធីពិសេសមួយនៃវេទិកា Nikkei Forum លើកទី២៩ ក្រោមមូលបទ "អនាគតនៃទ្វីបអាស៊ី"។ កម្មវិធីនេះត្រូវបានរៀបចំឡើងនៅទីក្រុងតូក្យូពីថ្ងៃទី២៣ ដល់ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤ ដោយមានការចូលរួមពីថ្នាក់ដឹកនាំតំបន់អាស៊ីល្បីៗ រួមទាំងនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីផងដែរ។ លោកជំទាវបានលើកឡើងពីគោលដៅអាកាសធាតុរបស់រដ្ឋាភិបាលកម្ពុជា តួនាទីរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការសម្របសម្រួលលំហូរហិរញ្ញប្បទានប្រកបដោយចីរភាព និងកិច្ចសហប្រតិបត្តិការក្នុងវិស័យហិរញ្ញវត្ថុនៅតំបន់អាស៊ាន។ លោកជំទាវក៏បានលើកគំនិតផ្តួចផ្តើម "ការដោះដូរការវិនិយោគមូលបត្របំណុលប្រកបដោយចីរភាព (sustainability bond investment swap)" ដែលជាដំណោះស្រាយថ្មីមួយសម្រាប់កិច្ចសហប្រតិបត្តិការ។ លោកជំទាវក៏បានសង្កត់ធ្ងន់លើតម្រូវការធនធានដើម្បីពង្រឹងភាពធន់នឹងអាកាសធាតុរបស់កម្ពុជា ដោយជំរុញឱ្យមានការគាំទ្រពីស្ថាប័នអន្តរជាតិសម្រាប់ប្រទេសដែលងាយរងគ្រោះនិងមានការបំភាយឧស្ម័នទាបក្នុងការសម្របខ្លួនទៅនឹងបរិស្ថានអាកាសធាតុថ្មី។



# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អញ្ជើញជាវាគ្មិនកិត្តិយសថ្លែងសុន្ទរកថាគន្លឹះ ស្ដីពី "រូបិយប័ណ្ណឌីជីថល និងការធ្វើរៀលូបនីយកម្មនៅកម្ពុជាឡើងវិញ"



នាថ្ងៃចន្ទ ១១កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញជាវាគ្មិនកិត្តិយសថ្លែងសុន្ទរកថាគន្លឹះ ស្ដីពី "រូបិយប័ណ្ណឌីជីថល និងការធ្វើរៀលូបនីយកម្មនៅកម្ពុជាឡើងវិញ"នៅក្នុងសិក្ខាសាលាស្ដីពី "ការប្រើប្រាស់ប្រាក់រៀល៖ ផែនទីឆ្ពោះទៅកាន់ការធ្វើរៀលូបនីយកម្មឡើងវិញ (The Riel Deal: A Roadmap for Re-rielization)។ សិក្ខាសាលានេះត្រូវបានសហការរៀបចំឡើងដោយ ស្ថានទូតបារាំងនៅកម្ពុជា សាកលវិទ្យាល័យ Grenoble Alpes នៅប្រទេសបារាំង និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (RULE) ដោយមានការចូលរួមដោយផ្ទាល់និងតាមប្រព័ន្ធអនឡាញពីសំណាក់អ្នកស្រាវជ្រាវ សាស្ត្រាចារ្យ និស្សិត និងតំណាងក្រសួង-ស្ថាប័នរដ្ឋនិងឯកជន សរុបប្រមាណ ៦០នាក់។ សិក្ខាសាលានេះក៏មានការចូលរួមជាភ្ញៀវកិត្តិយសពី **ឯកឧត្តមបណ្ឌិត សាន វឌ្ឍនា** រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា **ឯកឧត្តមបណ្ឌិត លុយ ចាន់ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និង**លោកស្រីបណ្ឌិត** Thi-Anh-Dao TRAN



តំណាងស្ថានទូតបារាំងនៅកម្ពុជា ផងដែរ។ តាមរយៈសុន្ទរកថាគន្លឹះ លោកជំទាវទេសាភិបាល បានលើកឡើងពីប្រវត្តិរូបិយវត្ថុចាប់តាំងពីអាណាចក្រហ្វូណន រហូតដល់សម័យកាលនៃការកកើតប្រាក់រៀលនិងប្រវត្តិប្រាក់រៀល ព្រមទាំងការអភិវឌ្ឍប្រព័ន្ធធនាគារនៅកម្ពុជា។ លើសពីនេះ លោកជំទាវបណ្ឌិតក៏បានបង្ហាញពីដំណើរវិវត្តប្រកបដោយស្ថិរភាពនៃអត្រាប្តូរប្រាក់រៀល ការដាក់ឱ្យដំណើរការស្តង់ដារខេអេចឃ្យូអរ ការតភ្ជាប់ប្រព័ន្ធទូទាត់ឆ្លងដែនជាមួយបណ្តាប្រទេសផ្សេងៗនៅក្នុងតំបន់និងពិភពលោក និងដំណើរវិវឌ្ឍន៍នៃប្រតិបត្តិការតាមប្រព័ន្ធបាគង។ គួររំលេចថា សិក្ខាសាលានេះជាផ្នែកមួយនៃគម្រោងស្រាវជ្រាវដែលសហការរួមគ្នារវាងសាកលវិទ្យាល័យ Grenoble Alpes សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្តនិងវិទ្យាសាស្រ្តសេដ្ឋកិច្ច និងធនាគារជាតិនៃកម្ពុជា ដែលផ្តោតចម្បងទៅលើការវិភាគអំពីស្ថានភាពដុល្លារូបនីយកម្មនៅកម្ពុជា និងការទាញយកប្រយោជន៍ពីឌីជីថលូបនីយកម្ម ដើម្បីលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល និងបរិយាបន្នហិរញ្ញវត្ថុ។



# ជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា ដឹកនាំគណៈប្រតិភូធនាគារជាតិនៃកម្ពុជា ចូលរួមកិច្ចប្រជុំរួមថ្នាក់រដ្ឋមន្ត្រីនិងទេសាភិបាលធនាគារកណ្តាលអាស៊ាន+៣




នាថ្ងៃសុក្រ ១០រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ដឹកនាំគណៈប្រតិភូធនាគារជាតិនៃកម្ពុជា ចូលរួមកិច្ចប្រជុំរួមថ្នាក់រដ្ឋមន្ត្រីនិងទេសាភិបាលធនាគារកណ្តាលអាស៊ាន+៣ នៅទីក្រុងបីលីស៊ី ប្រទេសហ្សកហ្ស៊ី។ កិច្ចប្រជុំនេះធ្វើឡើងក្រោមការដឹកនាំរបស់សហប្រធានកូរ៉េ និងឡាវ ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការ និងភាពរឹងមាំនៃសំណាញ់សុវត្ថិភាពក្នុងវិស័យហិរញ្ញវត្ថុ។ អង្គប្រជុំក៏បានឯកភាពទៅនឹងទិសដៅ ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុក្នុងតំបន់ ដែលរួមមាន ការពង្រឹងប្រសិទ្ធភាពពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (CMIM) ដែលជាសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុតំបន់ តាមរយៈការរៀបចំឧបករណ៍ហិរញ្ញប្បទានរហ័សសម្រាប់តំបន់ (RFA) ការធ្វើឱ្យកាន់តែប្រសើរឡើងនូវការងាររបស់អង្គភាព AMRO ជាពិសេស ការប្រែក្លាយអង្គភាព AMRO ឱ្យទៅជាឃ្លាំងចំណេះដឹងតំបន់ (Knowledge Hub) និងការបន្តអភិវឌ្ឍគំនិតផ្តួចផ្តើមទីផ្សារសញ្ញាប័ណ្ណអាស៊ាន (ABMI) ជាមួយនឹងការរៀបចំហិរញ្ញប្បទានសម្រាប់បង្ការហានិភ័យគ្រោះមហន្តរាយធម្មជាតិ (DRF) ជាដើម។ សេដ្ឋកិច្ចតំបន់អាស៊ាន+៣ ក្នុងឆ្នាំ២០២៣ បានកើនឡើង ៤,៣% ហើយរំពឹងថានឹងបន្តកើនឡើងលឿនជាងមុនបន្តិចដល់ ៤,៥% ក្នុងឆ្នាំ២០២៤នេះ ដោយសារការងើបឡើងវិញនៃការវិនិយោគ ការចំណាយ



របស់អ្នកប្រើប្រាស់ ការនាំចេញ និងទេសចរណ៍។ ទស្សនៈវិជ្ជមានចំពោះកំណើនសេដ្ឋកិច្ចនេះ អាចផ្តល់លទ្ធភាពដល់តំបន់អាស៊ាន+៣ ក្នុងការកសាងឡើងវិញនូវលំហគោលនយោបាយ (policy space) តាមរយៈការស្តារឡើងវិញនូវទ្រនាប់ថវិការដ្ឋ ការពង្រឹងចីរភាពថវិកា និងការបន្តរឹតបន្តឹងនយោបាយរូបិយវត្ថុតាមការចាំបាច់ បន្ទាប់ពីការខាតបង់ក្នុងអំឡុងពេលវិបត្តិកូវីដ-១៩។ អង្គប្រជុំបានអបអរសាទរនូវស្មារតីកិច្ចសហប្រតិបត្តិការក្នុងតំបន់ សម្រាប់ការឆ្ពោះទៅរកការងើបឡើងនៃសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងថាមភាព សំដៅឈានទៅរកការអភិវឌ្ឍជាសកលឱ្យកាន់តែបៃតង ធន់មាំ និងមានតុល្យភាពនិងសមភាពជាងមុន។ អង្គប្រជុំក៏បានគាំទ្រចំពោះប្រព័ន្ធពាណិជ្ជកម្មពហុភាគីដែលផ្អែកលើច្បាប់ដោយមិនមានការរើសអើង មានតម្លាភាព សមធម៌ បរិយាបន្ន យុត្តិធម៌ និងសេរីភាព និងការបើកចំហ។



# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

នាថ្ងៃចន្ទ ៦កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ដើម្បីពិនិត្យលើសេចក្តីព្រាងចុងក្រោយនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២១-២០៣០ នៅធនាគារជាតិនៃកម្ពុជា អគារសែនសុខ។ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២១-២០៣០នេះ គឺជាការធ្វើបច្ចុប្បន្នកម្មពីឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១៥-២០២៥ ដោយឡែកដំណើរការនៃការធ្វើបច្ចុប្បន្នកម្មឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ លើកទី៤នេះ ត្រូវបានពន្យារពេលដោយសារវិបត្តិកូវីដ-១៩។ នៅក្នុងកិច្ចប្រជុំលោកជំទាវ ទេសាភិបាល បានលើកឡើងថា ឯកសារដ៏មានសារៈសំខាន់នេះ នឹងជួយឱ្យវិស័យហិរញ្ញវត្ថុកម្ពុជាសម្រេចបានសមិទ្ធផលជាបន្តបន្ទាប់ទៀត ដែលជួយគាំទ្រនិងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាបន្ន រួមចំណែកកាត់បន្ថយភាពក្រីក្រ លើកកម្ពស់សមាហរណកម្មនៅក្នុងតំបន់និងអន្តរជាតិ។ ឯកសារនេះគ្រោងនឹងបញ្ចប់ជាស្ថាពរនៅអំឡុងឆមាសទី២ ឆ្នាំ២០២៤នេះ។







# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អញ្ជើញបំពេញទស្សនកិច្ចនៅសារមន្ទីរសេដ្ឋកិច្ចនៃធនាគារកណ្តាលបារាំង

នៅថ្ងៃចន្ទ ១២រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញបំពេញទស្សនកិច្ចនៅសារមន្ទីរសេដ្ឋកិច្ច (Citéco) នៃធនាគារកណ្តាលបារាំង នៅទីក្រុងប៉ារីស ប្រទេសបារាំង ដោយមានការទទួលបដិសណ្ឋារកិច្ចពី **លោក** Philippe Gineste ប្រធានសារមន្ទីរ។ ទស្សនកិច្ចនេះមានគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការរវាងសារមន្ទីរនៃធនាគារកណ្តាលទាំងពីរ។ សារមន្ទីរ Citéco ត្រូវបានបើកឱ្យចូលទស្សនាជាសាធារណៈ ដើម្បីផ្តល់ចំណេះដឹងផ្នែកសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងរូបិយវត្ថុ ជាពិសេសចំពោះយុវជន។ លោកជំទាវបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសារមន្ទីរ Citéco ដែលកន្លងមកបានចែករំលែកបទពិសោធន៍ និងមានកិច្ចសហការល្អជាមួយសារមន្ទីរសេដ្ឋកិច្ចនិងរូបិយវត្ថុ ព្រះស្រីឦសានវរ្ម័ន (ស.ស.រ) នៃធនាគារជាតិនៃកម្ពុជា។



# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ទទួលជួបសម្តែងការគួរសមនិងពិភាក្សាការងារជាមួយ ឯកឧត្តម Igor Driesmans ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំកម្ពុជា



*ឯកឧត្តម Igor Driesmans*
*ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំកម្ពុជា*



*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល*
*ធនាគារជាតិនៃកម្ពុជា*

នាថ្ងៃចន្ទ ៨រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១ ខែមេសា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ទទួលជួបសម្តែងការគួរសមនិងពិភាក្សាការងារជាមួយ **ឯកឧត្តម** Igor Driesmans ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំកម្ពុជា នៅធនាគារជាតិនៃកម្ពុជា អគារវត្តភ្នំ។ លោកជំទាវបានជម្រាបជូន ឯកឧត្តម ឯកអគ្គរដ្ឋទូត អំពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ច វិស័យធនាគារ ដុល្លារូបនីយកម្ម និងសកម្មភាពលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ព្រមទាំងការអភិវឌ្ឍប្រព័ន្ធទូទាត់ឌីជីថលទាំងក្នុងស្រុកនិងឆ្លងដែន។ ឯកឧត្តម ឯកអគ្គរដ្ឋទូត បានវាយតម្លៃខ្ពស់ចំពោះការរីកចម្រើនរបស់សេដ្ឋកិច្ចកម្ពុជា ក៏ដូចជាប្រព័ន្ធធនាគារ និងប្រព័ន្ធទូទាត់ ព្រមទាំងព្យាយាមជំរុញការវិនិយោគ ពាណិជ្ជកម្ម និងទេសចរណ៍ពីសហភាពអឺរ៉ុបនៅកម្ពុជា។



# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អនុញ្ញាតឱ្យប្រធានសមាគមធនាគារនៅកម្ពុជា និងសមាជិកក្រុមប្រឹក្សាភិបាលថ្មីចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ



*លោក រ័ត្ន សោភ័ណ*
*ប្រធានសមាគមធនាគារនៅកម្ពុជា*



*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល*
*ធនាគារជាតិនៃកម្ពុជា*

នាថ្ងៃអង្គារ ១៥កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជាអនុញ្ញាតឱ្យ**លោករ័ត្ន សោភ័ណ** ប្រធានសមាគមធនាគារនៅកម្ពុជា និងសមាជិកក្រុមប្រឹក្សាភិបាលថ្មី ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅធនាគារជាតិនៃកម្ពុជា អគារវត្តភ្នំ។ លោកប្រធានសមាគមបានជម្រាបជូនលោកជំទាវទេសាភិបាល អំពីគំនិតផ្តួចផ្តើមនានាដែលសមាគមបានដាក់ចេញសម្រាប់បន្តអនុវត្ត ដូចជា ការពង្រឹងអភិបាលកិច្ចផ្ទៃក្នុង កិច្ចការពារអតិថិជន និងការអប់រំផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងផ្នែកឌីជីថលជាដើម។ លោកប្រធានសមាគមក៏បានអបអរសាទរចំពោះការរីកចម្រើនរបស់វិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ក៏ដូចជាប្រព័ន្ធទូទាត់ ព្រមទាំងបានប្តេជ្ញាបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយ ធនាគារជាតិនៃកម្ពុជា ក្នុងការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយ ស្របតាមផែនការយុទ្ធសាស្ត្ររបស់ធនាគារជាតិនៃកម្ពុជា។ ជាមួយគ្នានេះក្រុមប្រឹក្សាភិបាលសមាគមក៏បានបង្ហាញការងារមួយចំនួនទៀតដែលបាននិងកំពុងអនុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យធនាគារ និងហិរញ្ញវត្ថុនៅប្រទេសកម្ពុជាផងដែរ។

# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា ទទួលជួបក្រុមបេសកកម្មអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣



*លោកបណ្ឌិត Hoe Ee Khor ប្រធានសេដ្ឋវិទូ អង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣*



*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា*

នាព្រឹកថ្ងៃចន្ទ ៦កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អនុញ្ញាតឱ្យក្រុមបេសកកម្មអង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ (AMRO) ដឹកនាំដោយ **លោកបណ្ឌិត** Hoe Ee Khor ប្រធានសេដ្ឋវិទូ ចូលជួបសម្តែងការគួរសម និងរាយការណ៍ជូនអំពីលទ្ធផលនៃការវាយតម្លៃបឋមលើស្ថានភាពសេដ្ឋកិច្ចកម្ពុជា បន្ទាប់ពីក្រុមបេសកកម្មបានមកបំពេញបេសកកម្មរយៈពេលពីរសប្តាហ៍កន្លងមក។ ក្រុមបេសកកម្មនៅតែបន្តមានសុទិដ្ឋិនិយម ចំពោះការងើបឡើងនៃសេដ្ឋកិច្ចកម្ពុជា ដោយបានព្យាករថាកំណើននៅឆ្នាំ២០២៤ នឹងមានកម្រិតខ្ពស់ជាងឆ្នាំ២០២៣ ហើយបន្តងើបឡើងខ្ពស់មួយកម្រិតទៀតក្នុងឆ្នាំ២០២៥ ខាងមុខ។ អតិផរណារំពឹងបន្តមានកម្រិតទាបត្រឹម ២,៥% នៅឆ្នាំ២០២៤ និង២០២៥។ ទោះយ៉ាងណា សេដ្ឋកិច្ចកម្ពុជាក៏អាចប្រឈមនឹងហានិភ័យមួយចំនួន ដូចជា ហានិភ័យនៃការថមថយនៃតម្រូវការខាងក្រៅ ប្រសិនបើសេដ្ឋកិច្ចនៃប្រទេសជាដៃគូពាណិជ្ជកម្មមានកំណើនទាបជាងការរំពឹងទុក ការបែងចែកភូមិសាស្ត្រសេដ្ឋកិច្ច និងការប្រែប្រួលអាកាសធាតុ ជាដើម។ ក្នុងឱកាសនោះ លោកជំទាវទេសាភិបាល បានថ្លែងអំណរគុណដល់ក្រុមបេសកកម្មដែលតែងតែជួយតាមដាន និងវាយតម្លៃស្ថានភាពសេដ្ឋកិច្ចកម្ពុជាជាប់ជាប្រចាំ។ លោកជំទាវទេសាភិបាលរង់ចាំស្វាគមន៍របាយការណ៍លម្អិតរបស់ក្រុមបេសកកម្ម និងអនុសាសន៍គោលនយោបាយ ដែលនឹងក្លាយជាធាតុចូលដ៏សំខាន់ សម្រាប់ការរៀបចំគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចកម្ពុជា។

# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា ជួបពិភាក្សាការងារជាមួយ ឯកឧត្តមបណ្ឌិត កៅ គឹមហួន អគ្គលេខាធិការអាស៊ាន

នាព្រឹកថ្ងៃសុក្រ ២រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ជួបពិភាក្សាការងារជាមួយ **ឯកឧត្តមបណ្ឌិត កៅ គឹមហួន** អគ្គលេខាធិការអាស៊ាន ក្នុងឱកាសនៃវេទិកា Nikkei Forum ក្រោមមូលបទ "អនាគតនៃទ្វីបអាស៊ី" នៅទីក្រុងតូក្យូ ប្រទេសជប៉ុន។ កិច្ចពិភាក្សាបានផ្តោតលើវឌ្ឍនភាពដ៏ប្រសើរនៃការធ្វើសមាហរណកម្មប្រព័ន្ធទូទាត់ក្នុងតំបន់អាស៊ាន ការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុប្រកបដោយចីរភាព។ ថ្នាក់ដឹកនាំទាំងពីរបានសង្កត់ធ្ងន់ពីសារៈសំខាន់ក្នុងការរក្សាចីរភាពនៃវឌ្ឍនភាពទាំងនេះ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចក្នុងតំបន់ឱ្យកាន់តែប្រសើរថែមទៀត។



# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា ជួបសម្ដែងការគួរសមជាមួយ ឯកឧត្តម នង សាកល ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសបែលហ្ស៊ិក លុចសំបួ ហូឡង់ និងអូទ្រីស

នៅថ្ងៃអាទិត្យ ១១រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ជួបសម្ដែងការគួរសមជាមួយ **ឯកឧត្តម នង សាកល** ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសបែលហ្ស៊ិក លុចសំបួ ហូឡង់ និងអូទ្រីស នាឱកាសដែលលោកជំទាវអញ្ជើញបំពេញបេសកកម្ម នៅប្រទេសបែលហ្ស៊ិក។ លោកជំទាវ ទេសាភិបាល បានថ្លែងសរសើរពីវឌ្ឍនភាពល្អនៃកិច្ចសហប្រតិបត្តិការរវាងកម្ពុជានិងបែលហ្ស៊ិក និងបានជម្រាបជូនពីកិច្ច-សហការល្អរវាងធនាគារជាតិនៃកម្ពុជានិងធនាគារកណ្ដាលបែលហ្ស៊ិក ក្នុងរយៈពេលជាងពីទសវត្សរ៍ចុងក្រោយនេះ។ លោកជំទាវ ក៏បានលើកឡើងពីការវិវត្តនៃឌីជីថលូបនីកម្មក្នុងវិស័យធនាគារកម្ពុជា ជាពិសេសក្នុងប្រព័ន្ធទូទាត់ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការធ្វើឌីជីថលូបនីកម្មសេដ្ឋកិច្ច និងសង្គមកម្ពុជា។ ធនាគារជាតិនៃកម្ពុជា បានអភិវឌ្ឍការទូទាត់អេឡិចត្រូនិក និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបាគង និងស្តង់ដារ QR Code ជាបន្តបន្ទាប់ ដែលបានធ្វើឱ្យការទូទាត់កាន់តែងាយស្រួល ភ្លាមៗ និងសុវត្ថិភាព និងបានភ្ជាប់ការទូទាត់នៅក្នុងស្រុករវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ដូចជាជាមួយប្រទេសជិតខាង។ បច្ចុប្បន្ន ប្រជាជនកម្ពុជាអាចទូទាត់ចេញពីគណនីប្រាក់រៀលរបស់ខ្លួននៅប្រទេសថៃ វៀតណាម និងឡាវ ហើយក្នុងពេលឆាប់ៗ នៅប្រទេសចិន ឥណ្ឌា និងម៉ាឡេស៊ី ។ល។ ហើយប្រជាជននៅប្រទេសទាំងនោះក៏អាចទូទាត់តាមប្រព័ន្ធ QR Code នៅកម្ពុជា ជាប្រាក់រៀលផងដែរ។



# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អញ្ជើញជួបពិភាក្សាការងារជាមួយ ឯកឧត្តម លុយ ដាវីត



នៅថ្ងៃចន្ទ ១២រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញជួបពិភាក្សាការងារ ជាមួយ **ឯកឧត្តម លុយ ដាវីត** ឯកអគ្គរាជទូត កម្ពុជាប្រចាំនៅសាធារណរដ្ឋបារាំងអ៊ីតាលី ព័រទុយហ្គាល់ ម៉ាល់តា ព្រះរាជាណាចក្រអេស្ប៉ាញ បូរីក្សត្រអង់ដ័រ និងបូរីក្សត្រម៉ូណាកូ។ ជំនួបនេះបានប្រព្រឹត្តិទៅនៅ និវេសនដ្ឋានឯកអគ្គរាជទូត នៅទីក្រុងប៉ារីស ប្រទេស បារាំង។ ឯកឧត្តម អគ្គរាជទូត បានថ្លែងអំណរគុណ លោកជំទាវ ដែលបានឆ្លៀតឱកាសមកទស្សនកិច្ច នៅនិវេសនដ្ឋានឯកអគ្គរាជទូត ក្នុងដំណើរបំពេញ បេសកកម្មរបស់លោកជំទាវនៅប្រទេសបារាំង និង បានជម្រាបជូនអំពីកិច្ចសហប្រតិបត្តិការល្អប្រសើរ រវាងកម្ពុជានិងបារាំង នាពេលថ្មីៗនេះ។ លោកជំទាវ បណ្ឌិតបានថ្លែងអំណរគុណឯកឧត្តម ឯកអគ្គរាជទូត និងបានជម្រាបជូនពីទំនាក់ទំនងដ៏ល្អប្រសើរ ក្នុង កិច្ចសហប្រតិបត្តិការរវាង ធនាគារជាតិនៃកម្ពុជា និង ធនាគារកណ្តាលបារាំង ចាប់តាំងពីការកកើត ធនាគារជាតិ នៃកម្ពុជា ក្នុងឆ្នាំ១៩៥៤ រហូតដល់បច្ចុប្បន្ន ជាពិសេស ក្នុងរយៈពេលប្រមាណ ៣០ ឆ្នាំចុងក្រោយនេះ ដែល ធនាគារកណ្តាលបារាំងបានបញ្ជូនជំនាញការមក ចូលរួមចំណែកអភិវឌ្ឍ ធនាគារជាតិនៃកម្ពុជា ក៏ដូចជា វិស័យធនាគារនៅប្រទេសកម្ពុជា។ លោកជំទាវបាន លើកឡើងផងដែរ អំពីការចូលរួមរបស់ធនាគារជាតិ នៃកម្ពុជា ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយ



ប្រទេសនិយាយភាសាបារាំង (ហ្វ្រង់កូហ្វូន) តាមរយៈកិច្ចប្រជុំនិងវេទិកាផ្សេងៗ ដើម្បីលើកកិត្យានុភាពរបស់កម្ពុជាលើឆាកអន្តរជាតិ។ ម៉្យាងទៀត លោកជំទាវទេសាភិបាល ក៏បានជម្រាបជូនឯកឧត្តម ឯកអគ្គរាជទូតអំពីការអភិវឌ្ឍនៃវិស័យធនាគារ និងការចូលរួមចំណែកក្នុងកិច្ចការការទូតឌីជីថល តាមរយៈការបង្កើនការតភ្ជាប់ប្រព័ន្ធទូទាត់ ក៏ដូចជាចែករំលែកបទពិសោធន៍កម្ពុជាក្នុងការអភិវឌ្ឍប្រព័ន្ធទូទាត់ជាមួយប្រទេសក្នុងតំបន់និងពិភពលោក ដូចជា ជាមួយប្រទេសនៅអាស៊ាន ចិន ឥណ្ឌា អាហ្វ្រិក (រវ៉ាន់ដា) អូសេអានី (កោះសូឡូម៉ុន ហ្វីជី) ជាដើម។



# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា អនុញ្ញាតឱ្យលោក Kenichiro Kashiwase ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ



*លោក Kenichiro Kashiwase ប្រធានបេសកកម្មថ្មីរបស់ IMF សម្រាប់កម្ពុជា*



*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា*

នារសៀលថ្ងៃអង្គារ ៥កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អនុញ្ញាតឱ្យ**លោក Kenichiro Kashiwase** ប្រធានបេសកកម្មថ្មីរបស់ IMF សម្រាប់កម្ពុជា ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារនៅធនាគារជាតិនៃកម្ពុជា អគារវត្តភ្នំ។ លោកជំទាវទេសាភិបាល បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះលោក Kenichiro និងបានជម្រាបជូនពីវឌ្ឍនភាពម៉ាក្រូសេដ្ឋកិច្ច និងវិស័យធនាគារនៅកម្ពុជា ព្រមទាំងសកម្មភាពលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល។ លើសពីនេះ លោកជំទាវក៏បានលើកឡើងពីកិច្ចសហប្រតិបត្តិការល្អរវាង ធនាគារជាតិនៃកម្ពុជា និង IMF ក៏ដូចជាប្រទេសជប៉ុន ផងដែរ។ នាឱកាសនោះ លោក Kenichiro បានជម្រាបជូនលោកជំទាវបណ្ឌិត ពីគម្រោងដំណើរទស្សនកិច្ចរបស់ក្រុមបេសកកម្មពិគ្រោះយោបល់មាត្រា IV (Article IV Consultation) នៅកម្ពុជាក្នុងពេលខាងមុខ និងបង្ហាញការគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការរៀបចំសន្និសីទម៉ាក្រូសេដ្ឋកិច្ចជារៀងរាល់ឆ្នាំ។ លោកជំទាវក៏បានថ្លែងអំណរគុណចំពោះ IMF និងរដ្ឋាភិបាលជប៉ុន ដែលបានរួមចំណែកក្នុងការចូលរួមក្នុងប្រតិបត្តិការរក្សាសន្តិភាព ព្រមទាំងផ្តល់ជំនួយសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងធនធានមនុស្សនៅកម្ពុជា ជាពិសេសតាមរយៈការបញ្ជូនជំនាញការ ក៏ដូចជាការផ្តល់វគ្គបណ្តុះបណ្តាលកសាងសមត្ថភាពដល់មន្ត្រីជំនាញរបស់ធនាគារជាតិនៃកម្ពុជា។

# លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល

## ធនាគារជាតិនៃកម្ពុជា ទទួលជួបសម្ដែងការគួរសមនិងពិភាក្សាការងារជាមួយ ឯកឧត្តម Santo Darmosumarto



*ឯកឧត្តម Santo Darmosumarto ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋឥណ្ឌូណេស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា*



*លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា*

នាថ្ងៃពុធ ៥រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៤ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ទទួលជួបសម្ដែងការគួរសម និងពិភាក្សាការងារជាមួយ **ឯកឧត្តម** Santo Darmosumarto ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋឥណ្ឌូណេស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅធនាគារជាតិនៃកម្ពុជា។ លោកជំទាវទេសាភិបាល បានស្វាគមន៍វត្តមានឯកឧត្តម ឯកអគ្គរដ្ឋទូតឥណ្ឌូណេស៊ីមកកាន់កម្ពុជា និងបាន



វាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការល្អរវាងប្រទេសទាំងពីរនាពេលកន្លងមក។ ក្នុងឱកាសនោះ ឯកឧត្តម Santo ក៏បានលើកសរសើរអំពីការរីកចម្រើននៃប្រព័ន្ធធនាគារនៅកម្ពុជា ជាពិសេសប្រព័ន្ធទូទាត់តាមឃ្យូអរកូត។ ក្នុងជំនួបនេះ លោកជំទាវទេសាភិបាលបានជម្រាបជូន ឯកឧត្តម ថា ធនាគារជាតិនៃកម្ពុជាមានកិច្ចសហប្រតិបត្តិការល្អជាមួយធនាគារកណ្តាលឥណ្ឌូណេស៊ី និងគ្រោងចុះអនុស្សរណៈយោគយល់ទ្វេភាគី ក្នុងឆ្នាំ២០២៤នេះ ដើម្បីបន្តពង្រឹងកិច្ចសហប្រតិបត្តិការបន្ថែមទៀត ជាពិសេសលើការពង្រឹងការអភិវឌ្ឍវិស័យធនាគារនៃប្រទេសទាំងពីរ និងការតភ្ជាប់ប្រព័ន្ធទូទាត់ទ្វេភាគី ដែលទាំងនេះនឹងរួមចំណែកជំរុញកំណើនភ្ញៀវទេសចរ ការដោះដូរពាណិជ្ជកម្ម និងការវិនិយោគទៅវិញទៅមក។ ឯកឧត្តម Santo ក៏បានបង្ហាញការគាំទ្រយ៉ាងពេញទំហឹងលើការពង្រឹងកិច្ចសហប្រតិបត្តិការទាំងនេះ។ លើសពីនេះ ឯកឧត្តមក៏បានវាយតម្លៃខ្ពស់ចំពោះសារមន្ទីរសេដ្ឋកិច្ចនិងរូបិយវត្ថុ ព្រះស្រីឦសានវរ្ម័ន (ស.ស.រ) របស់ធនាគារជាតិនៃកម្ពុជា និងគាំទ្រឱ្យមានកិច្ចសហប្រតិបត្តិការជាមួយសារមន្ទីររបស់ធនាគារកណ្តាលឥណ្ឌូណេស៊ី ព្រមទាំងបានស្នើសុំរៀបចំពិព័រណ៍មិនអចិន្ត្រៃយ៍នៅ ស.ស.រ នាពេលខាងមុខថែមទៀតផង។ ឯកឧត្តមក៏បានសរសើរពីគុណភាពអង្ករកម្ពុជា ដែលបាននាំចេញទៅទីផ្សារឥណ្ឌូណេស៊ី។ លោកជំទាវបណ្ឌិត បានជម្រាបជូនពីការចូលរួមរបស់ធនាគារជាតិនៃកម្ពុជា នៅក្នុងការគាំទ្រសេដ្ឋកិច្ចនិងសង្គមឱ្យដឹងថា របស់រាជរដ្ឋាភិបាល និងការពង្រឹងសន្តិសុខសាយប័រនៅក្នុងប្រព័ន្ធធនាគារកម្ពុជា តាមរយៈការបង្កើនការយល់ដឹងរបស់សាធារណជនទៅលើចំណេះដឹងផ្នែកហិរញ្ញវត្ថុ ការពង្រឹងសុវត្ថិភាពប្រព័ន្ធព័ត៌មានវិទ្យា និងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ។ ជារួម លោកជំទាវបណ្ឌិត និងឯកឧត្តមឯកអគ្គរដ្ឋទូត បានឯកភាពគ្នាលើការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍវិស័យធនាគាររបស់ប្រទេសទាំងពីរឱ្យកាន់តែរីកចម្រើនថែមទៀត។

# អត្រាប្តូរប្រាក់ប្រចាំខែ

(អត្រាប្តូរចុងខែ)

| ចុងខែ | អត្រាទីផ្សារ | | | | | អត្រាផ្លូវការ | | | គម្លាតអត្រាមធ្យម | |
|---|---|---|---|---|---|---|---|---|---|---|
| | ទិញ | លក់ | មធ្យម | ប្រែប្រួលប្រចាំខែ | | មធ្យម | ប្រែប្រួលប្រចាំខែ | | អត្រាផ្លូវការ-ទីផ្សារ | |
| | | | | +/- | % | | +/- | % | +/- | % |
| **២០២១** | | | | | | | | | | |
| កក្កដា | ៤.១០៧ | ៤.១១៧ | ៤.១១២ | ៥ | 0,១២ | ៤.0៧២ | -៣ | -0,0៧ | ៤0 | 0,៩៨ |
| សីហា | ៤.១១៩ | ៤.១២៩ | ៤.១២៤ | ១២ | 0,២៩ | ៤.0៨0 | ៨ | 0,២0 | ៤៤ | ១,0៤ |
| កញ្ញា | ៤.១១៩ | ៤.១៣0 | ៤.១២៥ | 0 | - | ៤.0៧៩ | -១ | -0,0២ | ៤៤ | ១,0៨ |
| តុលា | ៤.0៩៩ | ៤.១0៩ | ៤.១0៤ | -២0 | -0,៤៩ | ៤.0៦៦ | -១៣ | -0,៣២ | ៣៧ | 0,៩0 |
| វិច្ឆិកា | ៤.១0២ | ៤.១១៣ | ៤.១0៨ | ៣ | 0,0៧ | ៤.0៦៩ | ៣ | 0,0៧ | ៣៦ | 0,៨៨ |
| ធ្នូ | ៤.១0៩ | ៤.១១៨ | ៤.១១៤ | ៧ | 0,១៧ | ៤.0៧៤ | ៥ | 0,១២ | ៤0 | 0,៩៧ |
| **២០២២** | | | | | | | | | | |
| មករា | ៤.0៨៨ | ៤.0៩៨ | ៤.0៩៣ | -២១ | -0,៥១ | ៤.0៦៦ | -៨ | -0,២0 | -២៧ | -0,៦៦ |
| កុម្ភៈ | ៤.0៨៦ | ៤.0៩៤ | ៤.0៩១ | -២ | -0,0៥ | ៤.0៦៦ | 0 | 0,00 | -២៥ | -0,៦១ |
| មីនា | ៤.0៦៨ | ៤.0៧៨ | ៤.0៧៣ | -១៨ | -0,៤៤ | ៤.0៥0 | -១៦ | -0,៣៩ | -២៣ | -0,៥៧ |
| មេសា | ៤.0៦៨ | ៤.0៨0 | ៤.0៧៤ | 0 | 0,00 | ៤.0៤៦ | -៤ | -0,១0 | -២៨ | -0,៦៩ |
| ឧសភា | ៤.0៨៨ | ៤.0៩៧ | ៤.0៩៣ | ២0 | 0,៤៩ | ៤.0៦២ | ១៦ | 0,៤0 | ៣១ | 0,៧៥ |
| មិថុនា | ៤.0៩១ | ៤.១00 | ៤.0៩៦ | ៣ | 0,0៧ | ៤.0៧0 | ៨ | 0,២0 | ២២ | 0,៥៤ |
| កក្កដា | ៤.0៩៧ | ៤.១0៤ | ៤.១0១ | ៦ | 0,១៥ | ៤.0៩៩ | ២៩ | 0,៧១ | ២ | 0,0៤ |
| សីហា | ៤.១0៤ | ៤.១១៥ | ៤.១១0 | ៧ | 0,១៧ | ៤.១0៧ | ៨ | 0,២0 | -៥ | -0,១២ |
| កញ្ញា | ៤.១១៧ | ៤.១២៦ | ៤.១២២ | ១៣ | 0,៣២ | ៤.១១៩ | ១២ | 0,២៩ | -១ | -0,0២ |
| តុលា | ៤.១៣៥ | ៤.១៤៥ | ៤.១៤0 | ១៨ | 0,៤៤ | ៤.១៤១ | ២២ | 0,៥៣ | -១ | -0,0២ |
| វិច្ឆិកា | ៤.១១0 | ៤.១២0 | ៤.១១៥ | -២៥ | -0,៦0 | ៤.១២២ | -១៩ | -0,៤៦ | ២ | 0,0៤ |
| ធ្នូ | ៤.១១៣ | ៤.១២៣ | ៤.១១៨ | ៣ | 0,0៧ | ៤.១១៧ | -៥ | -0,១២ | ១ | 0,0១ |
| **២០២៣** | | | | | | | | | | |
| មករា | ៤.១0២ | ៤.១១៣ | ៤.១0៨ | -១១ | -0,២៧ | ៤.១0៤ | -១៣ | -0,៣២ | ២ | 0,0៤ |
| កុម្ភៈ | ៤.0៥0 | ៤.0៦៣ | ៤.0៥៧ | -៥២ | -១,២៧ | ៤.0៤៣ | -៦១ | -១,៤៩ | ៣ | 0,១0 |
| មីនា | ៤.0៥១ | ៤.0៦២ | ៤.0៥៧ | ១ | 0,0២ | ៤.0៥៤ | ១១ | 0,២៧ | ៥ | 0,១១ |
| មេសា | ៤.១១៤ | ៤.១២៦ | ៤.១២0 | ៦៣ | ១,៥៦ | ៤.១១៥ | ៦១ | ១,៥0 | ៥ | 0,១២ |
| ឧសភា | ៤.១១៦ | ៤.១២៦ | ៤.១២១ | ២ | 0,0៥ | ៤.១១៦ | ១ | 0,0២ | ១ | 0,0២ |
| មិថុនា | ៤.១២៦ | ៤.១៣៦ | ៤.១៣១ | ១0 | 0,២៤ | ៤.១៣0 | ១៤ | 0,៣៤ | ១ | 0,0១ |
| កក្កដា | ៤.១២៤ | ៤.១៣៤ | ៤.១២៩ | -២ | -0,0៥ | ៤.១៣0 | 0 | 0,00 | -១ | -0,0២ |
| សីហា | ៤.១៥១ | ៤.១៦១ | ៤.១៥៦ | ២៧ | 0,៦៥ | ៤.១៥៨ | ២៨ | 0,៦៨ | -៣ | -0,0៦ |
| កញ្ញា | ៤.១១៩ | ៤.១៣0 | ៤.១២៥ | -៣២ | -0,៧៧ | ៤.១២២ | -៣៦ | -0,៨៧ | ៣ | 0,0៦ |
| តុលា | ៤.១២៩ | ៤.១៣៧ | ៤.១៣៣ | ១0 | 0,២៤ | ៤.១៣៥ | ១៣ | 0,៣២ | ២ | 0,0៥ |
| វិច្ឆិកា | ៤.១១៣ | ៤.១២៣ | ៤.១១៨ | -១៦ | -0,៣៩ | ៤.១១៥ | -២0 | -0,៤៨ | ២ | 0,0៤ |
| ធ្នូ | ៤.0៨0 | ៤.0៩0 | ៤.0៨៥ | -៣៣ | -0,៨0 | ៤.0៨៥ | -៣0 | -0,៧៣ | 0 | 0,00 |
| **២០២៤** | | | | | | | | | | |
| មករា | ៤.0៨0 | ៤.0៩១ | ៤.0៨៦ | 0 | -0,៥៤ | ៤.0៨៣ | -២ | -0,0៥ | -១ | 0,0២ |
| កុម្ភៈ | ៤.0៦៤ | ៤.0៧៣ | ៤.0៦៩ | -១៦ | 0,៣៥ | ៤.0៦៩ | -១៤ | -0,៣៤ | ២ | 0,0៤ |
| មីនា | ៤.0៤0 | ៤.0៤៩ | ៤.0៤៥ | -២៤ | -0,២៧ | ៤.0៤១ | -២៨ | -0,៦៩ | ៤ | 0,0៩ |
| មេសា | ៤.0៤៧ | ៤.0៦0 | ៤.0៥៤ | -៧ | -0,១៧ | ៤.0៤៩ | -៨ | -0,១៩ | ៤ | 0,0៩ |
| ឧសភា | ៤.0៧៥ | ៤.0៨៥ | ៤.0៨0 | -២៨ | -0,៦៩ | ៤.0៧៧ | -២៨ | -0,៦៩ | -១ | -0,0១ |
| មិថុនា | ៤.១0៩ | ៤.១២0 | ៤.១១៤ | -៣៤ | -0,៨៣ | ៤.១១៣ | -៣៦ | -0,៨៨ | ៤ | 0,១0 |

## MONTHLY EXCHANGE RATE
(End-Month)

| End month | Parallel Market Rate | | | | | Official Exchange Rate | | | Spread | |
|---|---|---|---|---|---|---|---|---|---|---|
| | Purchase | Sale | Midpoint | Monthly Change | | Midpoint | Monthly Change | | Official-Market | |
| | | | | +/- | % | | +/- | % | +/- | % |
| **2021** | | | | | | | | | | |
| April | 4,068 | 4,083 | 4,076 | 6 | 0.15 | 4,048 | 3 | 0.07 | 28 | 0.68 |
| May | 4,107 | 4,116 | 4,112 | 39 | 0.96 | 4,072 | 24 | 0.59 | 37 | 0.90 |
| June | 4,102 | 4,112 | 4,107 | -5 | -0.12 | 4,075 | 3 | 0.07 | 29 | 0.71 |
| July | 4,107 | 4,117 | 4,112 | 5 | 0.12 | 4,072 | -3 | -0.07 | 40 | 0.98 |
| August | 4,119 | 4,129 | 4,124 | 12 | 0.29 | 4,080 | 8 | 0.20 | 44 | 1.04 |
| September | 4,119 | 4,130 | 4,125 | 0 | 0.00 | 4,079 | -1 | -0.02 | 44 | 1.08 |
| October | 4,099 | 4,109 | 4,104 | -20 | -0.49 | 4,066 | -13 | -0.32 | 37 | 0.90 |
| November | 4,102 | 4,113 | 4,108 | 3 | 0.07 | 4,069 | 3 | 0.07 | 36 | 0.88 |
| December | 4,109 | 4,118 | 4,114 | 7 | 0.17 | 4,074 | 5 | 0.12 | 40 | 0.97 |
| **2022** | | | | | | | | | | |
| January | 4,088 | 4,098 | 4,093 | -21 | -0.51 | 4,066 | -8 | -0.20 | 27 | 0.65 |
| February | 4,086 | 4,094 | 4,095 | -2 | -0.05 | 4,066 | 0 | 0.00 | 25 | 0.60 |
| March | 4,068 | 4,078 | 4,073 | -18 | -0.44 | 4,050 | -16 | -0.39 | 23 | 0.56 |
| April | 4,068 | 4,080 | 4,074 | 0 | 0.00 | 4,046 | -4 | -0.10 | 28 | 0.69 |
| May | 4,088 | 4,097 | 4,093 | 20 | 0.49 | 4,062 | 16 | 0.40 | 31 | 0.75 |
| June | 4,091 | 4,100 | 4,096 | 3 | 0.07 | 4,070 | 8 | 0.20 | 22 | 0.54 |
| July | 4,097 | 4,104 | 4,101 | 6 | 0.15 | 4,099 | 29 | 0.71 | 2 | 0.04 |
| August | 4,104 | 4,115 | 4,110 | 7 | 0.17 | 4,107 | 8 | 0.20 | -5 | -0.12 |
| September | 4,117 | 4,126 | 4,122 | 13 | 0.32 | 4,119 | 12 | 0.29 | -1 | -0.02 |
| October | 4,135 | 4,145 | 4,140 | 18 | 0.44 | 4,141 | 22 | 0.53 | -1 | -0.02 |
| November | 4,110 | 4,120 | 4,115 | -25 | -0.60 | 4,122 | -19 | -0.46 | 2 | 0.04 |
| December | 4,113 | 4,123 | 4,118 | 3 | 0.07 | 4,117 | -5 | -0.12 | 1 | 0.01 |
| **2023** | | | | | | | | | | |
| January | 4,102 | 4,113 | 4,108 | -11 | -0.27 | 4,104 | -13 | -0.32 | 2 | 0.04 |
| February | 4,050 | 4,063 | 4,057 | -52 | -1.27 | 4,043 | -61 | -1.49 | 3 | 0.10 |
| March | 4,051 | 4,062 | 4,057 | 1 | 0.02 | 4,054 | 11 | 0.27 | 5 | 0.11 |
| April | 4,114 | 4,126 | 4,120 | 63 | 1.56 | 4,115 | 61 | 1.50 | 5 | 0.12 |
| May | 4,116 | 4,126 | 4,121 | 2 | 0.05 | 4,116 | 1 | 0.02 | 1 | 0.02 |
| June | 4,126 | 4,136 | 4,131 | 10 | 0.24 | 4,130 | 14 | 0.34 | 1 | 0.01 |
| July | 4,124 | 4,134 | 4,129 | -2 | -0.05 | 4,130 | 0 | 0.00 | -1 | -0.02 |
| August | 4,151 | 4,161 | 4,156 | 27 | 0.65 | 4,158 | 28 | 0.68 | -3 | -0.06 |
| September | 4,119 | 4,130 | 4,125 | -32 | -0.77 | 4,122 | -36 | -0.87 | 3 | 0.06 |
| October | 4,129 | 4,137 | 4,133 | 10 | 0.24 | 4,135 | 13 | 0.32 | 2 | 0.05 |
| November | 4,113 | 4,123 | 4,118 | -16 | -0.39 | 4,115 | -20 | -0.48 | 2 | 0.04 |
| December | 4,080 | 4,090 | 4,085 | -33 | -0.80 | 4,085 | -30 | -0.73 | 0 | 0.00 |
| **2024** | | | | | | | | | | |
| January | 4,080 | 4,091 | 4,086 | 0.0 | 0.00 | 4,083 | -2 | -0.05 | -1 | -0.02 |
| February | 4,064 | 4,073 | 4,069 | -16.0 | -0.39 | 4,069 | -14 | -0.34 | 2 | 0.04 |
| March | 4,040 | 4,049 | 4,045 | -24.0 | -0.59 | 4,041 | -28 | -0.69 | 4 | 0.09 |
| April | 4,047 | 4,060 | 4,054 | -7 | -17 | 4,049 | -8 | -0.19 | 4 | 0.09 |
| May | 4,075 | 4,085 | 4,080 | -28 | -69 | 4,077 | -28 | -0.69 | -1 | -0.01 |
| June | 4,109 | 4,120 | 4,114 | -34 | -83 | 4,113 | -36 | -0.88 | 4 | -0.10 |

## ប្រាក់បញ្ញើនៅធនាគារទទួលប្រាក់បញ្ញើ និងបម្រែបម្រួលប្រចាំខែ

| | មេសា-២៤ | | ឧសភា-២៤ | | មិថុនា-២៣ | |
|---|---|---|---|---|---|---|
| | ប៊ីលានរៀល | % | ប៊ីលានរៀល | % | ប៊ីលានរៀល | % |
| **ប្រាក់បញ្ញើជារៀល** | | | | | | |
| ប្រាក់បញ្ញើចរន្ត | ៤.៦២០,៧ | ១,៥ | ៤.៥៥១,៧ | -១,៥ | ៥.១១១,៩ | ១០,៩ |
| ប្រាក់បញ្ញើសន្សំ | ៤.២៥៣,៦ | ០,២ | ៤.៤៣៤,៦ | ៤,១ | ៤.៨២៩,០ | ៨,១ |
| ប្រាក់បញ្ញើមានកាលកំណត់ | ១២.៥៤៦,៥ | ២,០ | ១២.៩៤៤,២ | ៣,០ | ១៣.១៤៣,៩ | ១,៥ |
| ប្រាក់បញ្ញើផ្សេងៗ | ៤៣៨,៥ | ៤,៩ | ៤៤៨,៥ | ២,២ | ៤៥៥,៧ | ១,៦ |
| **សរុប** | **២១.៨៥៩,៤** | **១,០** | **២២.៣៧៩,៦** | **២,៣** | **២៣.៥៤០,៥** | **៥,១៩** |
| **ប្រាក់បញ្ញើជារូបិយប័ណ្ណ** | | | | | | |
| ប្រាក់បញ្ញើចរន្ត | ២៧.៩៨១,៨ | -២,៧ | ២៨.៩៣១,២ | ៣,៣ | ២៩.៥៧៦,៥ | ២,១ |
| ប្រាក់បញ្ញើសន្សំ | ៤៤.២៧០,៥ | ២,០ | ៤៥.០៦៨,២ | ១,៨ | ៤៥.៨៦៤,១ | ១,៧ |
| ប្រាក់បញ្ញើមានកាលកំណត់ | ១០០.៩៦៩,០ | ២,១ | ១០៣.១៥២,២ | ២,១ | ១០៤.១២៨,៤ | ០,៩ |
| ប្រាក់បញ្ញើផ្សេងៗ | ៣.០៩០,៤ | ៦,៣ | ៣.០៦៣,៤ | ០,៨ | ៣.១៤៦,៥ | ២,៦ |
| **សរុប** | **១៧៦.៣១១,៧** | **១,៤** | **១៨០.២១៤,៩** | **២,១** | **១៨២.៧១៥,៥** | **១,៣** |
| **សរុបរួម** | **១៩៨.១៧១,០** | **១,៣** | **២០២.៥៩៣,៩** | **២,១** | **២០៦.២៥៦,០** | **១,៧** |

## DEPOSITS WITH DEPOSIT MONEY BANKS AND MONTHLY CHANGE

| | April-24 | | May-24 | | June-24 | |
|---|---|---|---|---|---|---|
| | KHR. Billion | % | KHR. Billion | % | KHR. Billion | % |
| DEPOSITS IN KHR. | | | | | | |
| Demand deposits | 4,620.7 | 1.5 | 4,551.7 | -1.5 | 5,111.9 | 10.9 |
| Savings deposits | 4,253.6 | 0.2 | 4,434.6 | 4.1 | 4,829.0 | 8.1 |
| Fixed deposits | 12,546.5 | 2.0 | 12,944.2 | 3.0 | 13,143.9 | 1.5 |
| Others | 438.5 | 4.9 | 448.5 | 2.2 | 455.7 | 1.6 |
| **Total** | **21,859.4** | **1.0** | **22,379.6** | **2.3** | **23,540.5** | **5.19** |
| DEPOSITS IN FOREIGN CURRENCY | | | | | | |
| Demand deposits | 27,981.8 | -2.7 | 28,931.2 | 3.3 | 29,576.5 | 2.1 |
| Savings deposits | 44,270.5 | 2.0 | 45,068.2 | 1.8 | 45,864.1 | 1.7 |
| Fixed deposits | 100,969.0 | 2.1 | 103,152.2 | 2.1 | 104,128.4 | 0.9 |
| Others | 3,090.4 | 6.3 | 3,063.4 | 0.8 | 3,146.5 | 2.6 |
| **Total** | **176,311.7** | **1.4** | **180,214.9** | **2.1** | **182,715.5** | **1.3** |
| **GRAND TOTAL** | **198,171.0** | **1.3** | **202,593.9** | **2.1** | **206,256.0** | **1.7** |

# ឥណទានផ្តល់ដោយធនាគារទទួលប្រាក់បញ្ញើតាមប្រភេទជំនួញ និងបម្រែបម្រួលប្រចាំខែ

| | មេសា-២៤ | | ឧសភា-២៤ | | មិថុនា-២៤ | |
|---|---|---|---|---|---|---|
| | ប៊ីលានរៀល | % | ប៊ីលានរៀល | % | ប៊ីលានរៀល | % |
| **គ្រឹះស្ថានហិរញ្ញវត្ថុ** | **៧.៥២៥,៥** | **-៣,៩** | **៧.៣៦៩,០** | **-២,១** | **៧.០២១,៩** | **-៤,៧** |
| ធនាគារជាតិនៃកម្ពុជា | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| គ្រឹះស្ថានហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | ៥.៧២៧,៩ | -៤,២ | ៥.៥៩៤,២ | -២,៣ | ៥.២៥៥,៤ | -៦,១ |
| គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗទៀត | ១.៧៩៧,៦ | -៣,១ | ១.៧៧៤,៧ | -១,៣ | ១.៧៦៦,៦ | -០,៥ |
| **គ្រឹះស្ថានមិនបម្រើសេវាហិរញ្ញវត្ថុ** | **១៦១.៨៧៦,៥** | **០,៦** | **១៦១.៤២៦,២** | **-០,៣** | **១៦០.៨៩៣,៩** | **-០,៣** |
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១៩.៣៣៩,៣ | ០,៥ | ១៩.២៥០,៧ | -០,៥ | ១៩.០៩៥,៨ | -០,៨ |
| ឧស្សាហកម្មរ៉ែ | ១.១០៦,០ | ១,៦ | ១.១៣៥,៣ | ២,៧ | ១.១៥៣,៩ | ១,៦ |
| កម្មន្តសាលកម្ម | ៩.៤៩៤,៥ | ១,៧ | ៩.៤៤៧,៧ | -០,៥ | ៩.៣៨០,៥ | -០,៧ |
| ការផ្គត់ផ្គង់សេវាសាធារណៈ | ២.៤០៥,៣ | -០,៤ | ២.៤៨៩,៣ | ៣,៥ | ២.៥០៣,៧ | ០,៦ |
| សំណង់ | ២០.៤៣១,៧ | -១,៩ | ២០.៤៣៦,៦ | ០,០ | ២០.៦០០,១ | ០,៨ |
| ការជួញដូរដុំ | ១៨.៩៦១,១ | -១,៦ | ១៨.៩៥១,៩ | ០,០ | ១៨.៦២៩,១ | -១,៧ |
| ការជួញដូររាយ | ៣៧.៣៥២,៤ | ០,៥ | ៣៧.៣៣៦,៨ | ០,០ | ៣៧.០៤៩,៤ | -០,៨ |
| សណ្ឋាគារ និងភោជនីយដ្ឋាន | ៨.៤៥០,៨ | ០,៥ | ៨.១៣៦,៧ | -៣,៧ | ៨.១២០,៨ | -០,២ |
| ដឹកជញ្ជូន និងស្តុកបណ្តោះអាសន្ន | ៦.៤៣៣,៧ | ៦,២ | ៦.៣៥៥,៣ | -១,២ | ៦.៣១០,៨ | -០,៧ |
| បណ្តាញព័ត៌មាននិងទូរគមនាគមន៍ | ១.០៩២,៧ | ១,៨ | ១.០២៩,៥ | -៥,៨ | ១.០៥៩,៣ | ២,៩ |
| អាជីវកម្មជួលនិងភតិសន្យា(មិនរាប់បញ្ចូលភតិសន្យានិងការជួលអចលនទ្រព្យ) | ២.៨៤៦,៤ | -០,៣ | ២.៩២០,១ | ២,៦ | ២.៨៦២,៣ | -២,០ |
| ការជួញដូរអចលនទ្រព្យ | ២២.៨៦៧,៧ | ៣,១ | ២២.៨២១,៩ | -០,២ | ២៣.៣៤០,៣ | ២,៣ |
| សេវាកម្មមិនមែនហិរញ្ញវត្ថុផ្សេងៗ | ១១.០៩៤,៨ | ១,១ | ១១.១១៤,៣ | ០,២ | ១០.៧៨៨,០ | -២,៩ |
| **ឥម្រូវការផ្ទាល់ខ្លួន** | **៤៨.៥២១,៣** | **-២,៤** | **៤៨.៦៦៦,០** | **០,៣** | **៤៨.៩៨១,៤** | **០,៦** |
| ការឱ្យខ្ចីជាបុគ្គល | ២០.០២៣,៧ | -២,៥ | ២០.៣៣៩,៩ | ១,៦ | ២០.៨៤៥,៨ | ២,៥ |
| ការឱ្យខ្ចីតាមប័ណ្ណឥណទាន | ៧២៩,៧ | ២,៩ | ៧២០,៧ | -១,២ | ៧៣៣,៦ | ១,៨ |
| ការឱ្យខ្ចីទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន | ២៧.៧៦៨,០ | -២,៤ | ២៧.៦០៥,៤ | -០,៦ | ២៧.៤០២,០ | -០,៧ |
| **ឥណទានផ្សេងៗ** | **២.៩២៦,៧** | **៦,៣** | **២.៩៦២,២** | **១,២** | **២.៩៣០,៥** | **-១,១** |
| **សរុបឥណទានដុល** | **២២០.៨៥០,១** | **-០,២** | **២២០.៤២៣,៣** | **-០,២** | **២១៩.៨២៧,៧** | **-០,៣** |

# CREDIT GRANTED BY DEPOSIT MONEY BANKS CLASSIFIED BY INDUSTRY AND MONTHLY CHANGE

| | April-24 | | May-24 | | June-24 | |
|---|---|---|---|---|---|---|
| | KHR. Billion | # | KHR. Billion | # | KHR. Billion | # |
| **FINANCIAL IN STITUTIONS** | **6,981.7** | **-0.5** | **6,897.2** | **-1.2** | **6,736.4** | **-2.3** |
| National Bank of Cambodia | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| Depository Institutions | 5,255.4 | 0.0 | 5,130.3 | -2.4 | 4,939.4 | -3.8 |
| Other Financial Institutions | 1,757.3 | -0.5 | 1,766.9 | 0.5 | 1,796.9 | 1.7 |
| **NON-FINANCIAL INSTITUTIONS** | **161,889.0** | **0.6** | **163,896.0** | **1.2** | **165,665.6** | **1.8** |
| Agriculture, Forestry and Fishing | 19,333.2 | 0.1 | 19,191.1 | -0.7 | 19,178.2 | 0.0 |
| Mining and Quarrying | 1,167.0 | 1.1 | 1,195.1 | 2.3 | 1,169.0 | -2.2 |
| Manufacturing | 9,274.4 | -1.1 | 9,431.0 | 1.6 | 9,503.7 | 0.7 |
| Utilities | 2,527.3 | 0.9 | 2,551.4 | 0.9 | 2,624.2 | 2.8 |
| Construction | 20,805.9 | 0.9 | 20,886.5 | 0.3 | 22,224.1 | 6.2 |
| Wholesale Trade | 18,868.8 | 1.2 | 18,980.9 | 0.5 | 19,326.0 | 1.8 |
| Retail Trade | 37,185.9 | 0.3 | 37,501.0 | 0.5 | 37,601.3 | 0.2 |
| Hotels and Restaurants | 8,136.6 | 0.1 | 8,193.2 | 0.6 | 8,206.9 | 0.1 |
| Transport and Storage | 6,385.1 | 1.1 | 6,421.6 | 0.5 | 6,390.5 | -0.4 |
| Information Media and Telecommunications | 1,061.0 | 0.1 | 1,052.1 | -0.8 | 1,035.7 | -1.5 |
| Rental and Operational Leasing Activities | 2,842.3 | -0.7 | 3,002.0 | 5.4 | 2,894.2 | -3.6 |
| Real Estate Activities | 23,672.5 | 1.4 | 24,489.1 | 3.3 | 24,663.3 | 0.7 |
| Other Financial Services | 10,829.1 | 0.3 | 11,000.0 | 1.5 | 10,848.5 | -1.3 |
| **PERSONAL ESSENTIALS** | **49,262.4** | **0.5** | **49,002.7** | **0.5** | **49,842.3** | **1.6** |
| Personal Lending | 21,031.1 | 0.8 | 21,022.5 | 0.0 | 21,489.1 | 2.1 |
| Credit Card | 740.8 | 0.9 | 749.0 | 1.1 | 782.1 | 4.3 |
| Mortgages, Owner-Occupied Housing only | 27,490.5 | 0.3 | 27,231.2 | -0.9 | 27,571.1 | 1.2 |
| **OTHER LENDING** | **2,897.6** | **-1.1** | **2,941.1** | **1.4** | **3,027.8** | **2.9** |
| **TOTAL GROSS LOAN** | **221,030.7** | **0.5** | **222,737.0** | **0.7** | **225,272.1** | **1.1** |

# ការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអង្គការមិនមែនរដ្ឋាភិបាល

| | មេសា-២៤ | ឧសភា-២៤ | មិថុនា-២៤ |
|---|---|---|---|
| ចំនួនការិយាល័យកណ្តាល | ៨៧ | ៨៧ | ៨៨ |
| ចំនួនសាខាខេត្ត / ក្រុង | ៣១០ | ៣០៩ | ៣០៩ |
| ចំនួនសាខាស្រុក / ខណ្ឌ | ៥១៦ | ៥១៥ | ៥១៥ |
| ចំនួនអ្នកស្នើសុំឥណទាន | ១.៦០៦.០៤៥ | ១.៦០៦.៧៧៦ | ១.៦០១.៩០៧ |
| ប្រាក់កម្ចី (គិតជាប៊ីលានរៀល) | ២០.៩៧៥ | ២១.០៧៦ | ២១.២៥៦ |
| អត្រាការប្រាក់ប្រចាំខែ | ១,០%-១,៥% | ១,០%-១,៥% | ១,០%-១,៥% |
| អត្រាការប្រាក់ប្រចាំឆ្នាំ | ១២,១%-១៨,១% | ១២,១%-១៨,១% | ១២,០%-១៨,២% |

# CREDIT GRANTED BY MICRO-FINANCE INSTITUTIONS AND NON-GOVERNMENT ORGANIZATIONS

| | April-24 | May-24 | June-24 |
|---|---|---|---|
| Number of Head Office | 87 | 87 | 88 |
| Number of Branches in Province / Krong | 310 | 309 | 309 |
| Number of Branches in District / Khan | 516 | 515 | 515 |
| Number of Borrowers | 1,606,045 | 1,606,776 | 1,601,907 |
| Loan Outstanding (In KHR Billion) | 20,975 | 21,076 | 21,256 |
| Monthly Interest Rate | 1.0%-1.5% | 1.0%-1.5% | 1.0%-1.5% |
| Annually Interest Rate | 12.1%-18.1% | 12.1%-18.1% | 12.0%-18.2% |

# ការផាត់ទាត់មូលប្បទានបត្រតាមរយៈសភាផាត់ទាត់

| | មេសា-២៤ | ឧសភា-២៤ | មិថុនា-២៣ | សរុប |
|---|---|---|---|---|
| **មូលប្បទានបត្រ ជាប្រាក់រៀល** | | | | |
| ចំនួនថ្ងៃផាត់ទាត់ | ២០ | ២០ | ១៩ | ៥៩ |
| ចំនួនមូលប្បទានបត្របានទូទាត់ | ២.៧១៨ | ២.៧៧៣ | ២.៦៣៩ | ៨.១៣០ |
| ចំនួនទឹកប្រាក់សរុប (ប៊ីលានរៀល) | ១.៧៥០,៦ | ១.៧៤៥,៩ | ១.៤៧៦,០ | ៤.៩៧២,៥ |
| ចំនួនមូលប្បទានបត្របានទូទាត់ក្នុងថ្ងៃ | ១៣៦ | ១៣៩ | ១៣៩ | ១៣៨ |
| ទឹកប្រាក់ជាមធ្យមប្រចាំថ្ងៃ (ប៊ីលានរៀល) | ៨៧,៥ | ៨៧,៣ | ៧៧,៧ | ៨៤,១ |
| ចំនួនមូលប្បទានបត្របញ្ជូនត្រឡប់ | ១៤ | ១១ | ៦ | ៣១ |
| ជាទឹកប្រាក់បញ្ជូនត្រឡប់សរុប (ប៊ីលានរៀល) | ៩៣,២៥ | ៣,២៧ | ១,៧៣ | ៩៨,២៥ |
| **មូលប្បទានបត្រ ជាប្រាក់ដុល្លារអាមេរិក** | | | | |
| ចំនួនថ្ងៃផាត់ទាត់ | ២០ | ២០ | ១៩ | ៦៣ |
| ចំនួនមូលប្បទានបត្របានទូទាត់ | ៨៣.១៨៤ | ៨៧.៥៧៨ | ៧៩.៥៤២ | ២៥០.៣០៤ |
| ចំនួនទឹកប្រាក់សរុប (លានដុល្លារអាមេរិក) | ៣.៧៣១,៥ | ៤.០៤០,០ | ៣.៧២៦,២ | ១១.៤៩៧,៧ |
| ចំនួនមូលប្បទានបត្របានទូទាត់ក្នុងថ្ងៃ | ៤.១៥៩ | ៤.៣៧៩ | ៤.១៨៦ | ៤.២៤១,៣ |
| ទឹកប្រាក់ជាមធ្យមប្រចាំថ្ងៃ (លានដុល្លារអាមេរិក) | ១៨៦,៦ | ២០២ | ១៩៦,១ | ១៩៤,៩ |
| ចំនួនមូលប្បទានបត្របញ្ជូនត្រឡប់ | ៨៤៧ | ៩៨៩ | ៧៩៧ | ២.៦៣៣ |
| ទឹកប្រាក់បញ្ជូនត្រឡប់សរុប (លានដុល្លារអាមេរិក) | ៥៦,៥ | ៧០,២ | ១៣០,៥ | ២៥៧,២ |

## CHECKS CLEARING THROUGH CLEARING HOUSE

| | April-24 | May-24 | June-24 | Total |
|---|---|---|---|---|
| **KHR-DENOMINATED CHECKS CLEARING** | | | | |
| Number of Working Day | 20 | 20 | 19 | 59 |
| Number of Checks Cleared | 2,718 | 2,773 | 2,639 | 8,130 |
| Total Amount (In KHR Billion) | 1,750.6 | 1,745.9 | 1,476.0 | 4,972.5 |
| Number of Checks Cleared Per Day | 136 | 139 | 139 | 138 |
| Daily Average Amount (In KHR Billion) | 87.5 | 87.3 | 77.7 | 84.1 |
| Number of Checks Returned | 14 | 11 | 6 | 31 |
| Amounts of Checks Returned (In KHR Billion) | 93.25 | 3.27 | 1.73 | 98.25 |
| **USD-DENOMINATED CHECKS CLEARING** | | | | |
| Number of Working Day | 20 | 20 | 19 | 63 |
| Number of Checks Cleared | 83,184 | 87,578 | 79,542 | 250,304 |
| Total Amount (In USD Million) | 3,731.5 | 4,040.0 | 3,726.2 | 11,497.7 |
| Number of Checks Cleared Per Day | 4,159 | 4,379 | 4,186 | 4,241.3 |
| Daily Average Amount (In USD Million) | 186.6 | 202 | 196.1 | 194.9 |
| Number of Checks Returned | 847 | 989 | 797 | 2,633 |
| Amounts of Checks Returned (In USD Million) | 56.5 | 70.2 | 130.5 | 257.2 |

# ប្រព័ន្ធធនាគារកម្ពុជា (ខែមិថុនា ឆ្នាំ២០២៤)

## ធនាគារជាតិនៃកម្ពុជា

### ៥៩ ធនាគារពាណិជ្ជ

**២៨ បង្កើតក្នុងស្រុក**

១ ព.ណ.ក្រៅប្រទេស
២ កម្ពុជាអាស៊ី
៣ កាណាឌីយ៉ា
៤ ធនាគារវឌ្ឍនៈ
៥ អេស៊ីលីដា
៦ ស្ថាបនា
៧ ប៊ូយ៉ុងខ្មែរ
៨ ភ្នំពេញពាណិជ្ជ
៩ ប្រៃសណីយ៍
១០ ឈីហ្វ
១១ ប៊ី.អាយ.ស៊ី
១២ ព្រីនស៍
១៣ ជីបម៉ុង
១៤ អេស៊ា-ប៉ាស៊ីហ្វិក
១៥ ផេនដា ខមមើសល
១៦ អភិ.ជនបទ និងកសិ.
១៧ សហ. ធុនតូចនិងមធ្យម
១៨ ពាណិជ្ជ អាល់ហ្វា
១៩ អេសប៊ីអាយលីហ្សូរ
២០ ធនាគារហត្ថា
២១ រួយលី
២២ វីង
២៣ ហេងហ៊ី
២៤ អូរៀនថល
២៥ ប្រ៊ីដ
២៦ ស៊ីស៊ីយូ
២៧ ហេង ហ្វឹង
២៨ អាយភីយូ

**១១ សាខាបរទេស**

១ ធ.ពាណិជ្ជទី១
២ ធ.ក្រុងថៃ
៣ ធនាគារចិន
៤ ធនាគារមេហ្គា
៥ អាយស៊ីប៊ីស៊ី
៦ ធនាគារតៃវ៉ាន់
៧ ធនាគារបាងកក
៨ ធនាគារកសិកន
៩ ធនាគារមីហ្ស៊ូហូ
១០ ធ. វៀតណាម
១១ អ៊ិនដាសស្រៀល

**២០ បុត្តសម្ព័ន្ធ**

១ កម្ពុជាពាណិជ្ជ
២ សាធារណៈ
៣ មេយប៊ែង
៤ ជេ ត្រាស់ រ៉ូយ៉ាល់
៥ វឌ្ឍនៈអាស៊ី
៦ វិនិយោគ និងអភិ.
៧ ស៊ិនហានខ្មែរ
៨ អ អេច ប៊ី
៩ ស៊ីអាយ អឹមប៊ី
១០ សាខម ប៊ែង
១១ ហុងលីអ៊ុង
១២ ធនាគារកាថេ
១៣ សហពាណិជ្ជ
១៤ ហ្វីលីព
១៥ សៃហ្គន-ហាណូយ
១៦ ប្រេដប៊ែង
១៧ ឌីជីប៊ី
១៨ ធនាគារ អ៊ូរី
១៩ ធនាគារ អ៊ឹមប៊ី
២០ ខេប៊ីប្រាសាក់

### ៩ ធនាគារឯកទេស

**៤ បង្កើតឡើងក្នុងស្រុក**

១ អានកូ
២ អេវើប្រ៊្ហស៍
៣ ឯកទេស ម៉ារីថាម
៤ ដូនពេញ

**៥ ធនាគារបរទេស**

១ ភីអេចអែសអឹមអ៊ី
២ ខេប៊ី ដេហាន
៣ អង្គរកាពីតាល់
៤ អ៊ីអន
៥ សារ់ធើន ឃែភីថល

### ៥ ការិយាល័យតំណាង

១ ស្តង់ដារឆាទើរែត
២ ធ.វិ.អ.វៀតណាម
៣ ធ.ស៊ូមីតូម៉ូមីតស៊ុយ
៤ ធនាគារ សៀងហៃ
៥ អិចផត-អ៊ីមផត ប៊ែង

### ២០៣ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានឥណទានជនបទ

**៤ ទទួលប្រាក់បញ្ញើ**

១ អម្រឹត ម.ក
២ អេ អឹម ខេ
៣ អិល អូ អិល ស៊ី
៤ មហានគរ ម.ក

**៨៤ ផ្តល់ឥណទាន**

១ ស៊ីលានិធិ
២ វើលខម
៣ មាក់ស៊ីម៉ា
៤ ពលរដ្ឋរុងរឿង
៥ ណុងហឹប
៦ ហ្វាមើរ
៧ ហ្វឺស
៨ វ៉ាយស៊ីភី
៩ សំរិទ្ធិស័ក
១០ ខេមា
១១ ខេមរៈ
១២ ប្រាយ៉ម
១៣ សូណាត្រា
១៤ ចម្រើន
១៥ អាក់ទីវភីពល
១៦ បាយ៉ន
១៧ បរិបូរណ៍
១៨ ឃ្វីន
១៩ ស៊ីធី
២០ អមតៈ
២១ សច្ចៈ
២២ អូរ៉ូ
២៣ និរន្តរ
២៤ ខ្មៃលតា
២៥ សេនជូរី
២៦ ប៊ីអេអឹមស៊ី
២៧ ពិភពថ្មី
២៨ សិរីឧត្តម
២៩ សម្បត្តិ
៣០ ប៊ីអេនខេស៊ី
៣១ ប៊ែមប៊ូ
៣២ សហគ្រិនភាព
៣៣ ឆាយលីស
៣៤ ធីប៊ីប៊ី
៣៥ រ៉ូយ៉ាល់
៣៦ សាន់នី
៣៧ ហ្វូណន
៣៨ សម្ព័ន្ធសហគ្រាស
៣៩ សាមគ្គី
៤០ ខេមបូឌា ឡេប៊ី
៤១ ខេម ខាប់ភីថល
៤២ គង្គា ឃែភីថល
៤៣ ហ្វូតាបា
៤៤ អ៊ីខ្មៃមីតស៊ុ
៤៥ ម៉ាខ្មែរ
៤៦ សហាការ
៤៧ ហ្គោលដិន
៤៨ ជោគជ័យ
៤៩ សប្បាយ
៥០ ជេត ឃែស
៥១ លីដ
៥២ អិល ប៊ី ភី
៥៣ ប្រសិទ្ធភាព
៥៤ ធី & ហ្វ
៥៥ អនាគត
៥៦ ហ្វ្រូវ
៥៧ បៃតង
៥៨ មីយ៉ា
៥៩ ឡេង ណាវ៉ាត្រា
៦០ វិថី
៦១ ទ្រព្យខ្ញុំ
៦២ ខ្មែរ
៦៣ ភីជី
៦៤ ជេស៊ី
៦៥ ស៊ីអិមខេ
៦៦ រ៉ូល្យា
៦៧ អិលស៊ីអេច
៦៨ ហ្វាមីលី
៦៩ ប្រពៃ
៧០ ស៊ិកធីស៊ិកស៍
៧១ ជីប៊ី
៧២ អេវើហ្គ្រីន
៧៣ វ៉ាយអិលភី
៧៤ សារ៉ាត រុងរឿង
៧៥ មែងហ្គោ
៧៦ ខូវីច ម៉ាយក្រូហ្វាយ
៧៧ វិវឌ្ឍន៍ ហ្គោលឌិន
៧៨ សាយ ហូសថល
៧៩ សុខសាន្ត
៨០ អេអិមហ្សេត
៨១ ជេកស៍
៨២ អ៊ីស្ត មីក្រូ ម.ក
៨៣ វ៉ាហ្វូកូ
៨៤ អេច អេហ្វ ស៊ី

**១១៥ ឥណទានជនបទ**

១ ជូ ជីវ័ន
២ គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ
៣ បវរ
៤ ពាយ័ព្យ
៥ សេន
៦ មិត្តភាព ហ្វាយនែន
៧ អិល អ៊ី ឌី អេ ឃែភីថល
៨ លីដ-ធី អាយ ភី អេស
៩ ដៃគូ
១០ ព្រះខ័ន អភិវឌ្ឍន៍
១១ ក្រេប៉ូ ហ្វាយនែន
១២ វី.ភី ឌិច
១៣ សិរីសួស្តី
១៤ អូស៊ុីដាហ្វ
១៥ ជ ម៉ឺជីង
១៦ ហ៊ីគាន
១៧ កូនខ្មែរមង្គលហិរញ្ញវត្ថុ
១៨ មានជ័យ
១៩ ប្រសើរ
២០ មាគ៌ា
២១ ខេភីស៊ីអេ
២២ ដាកូ
២៣ សំណាងប្រតិបត្តិការ
២៤ ស្មាយល៍ ឃែភីថល
២៥ គុណភាព
២៦ សំរឹទ្ធ ពេជ្រ
២៧ ប៊ី.វ៉ាយ.ជី
២៨ ឃ្វិក អមតៈ
២៩ អិលអេច
៣០ បៃតង
៣១ ខេ.ឌី.អូ
៣២ ជុំ សំណាង
៣៣ ខេម
៣៤ ឥណទាន អ៊ីហ្សី
៣៥ ក្រុងខ្មែរ ហ្វាយនែន
៣៦ មរតក អភិវឌ្ឍន៍
៣៧ កល្យាណ អភិវឌ្ឍន៍
៣៨ ភូមិន្ទ
៣៩ វីរៈបុត្រ
៤០ ពន្លឺកសិករខ្មែរ ភី
៤១ ឥណទាន ជនបទខ្មែរ
៤២ អេស អេច ជី
៤៣ អរ អេន ឌី ប៊ី
៤៤ ផ្កាឈូក
៤៥ សុខសប្បាយ
៤៦ ខេ.ខេ.ស៊ី.អិម
៤៧ វ៉ាដូជីកូ
៤៨ ប្រសិទ្ធិភាព
៤៩ ហ្គូបល ឡែនឌីង ព
៥០ អិល ឌី អេ
៥១ ឥណទាននារី
៥២ ពិដោរ
៥៣ ស្កាយ ឡាយ
៥៤ តារា
៥៥ កូនកសិករ
៥៦ គ្រួសារឥណទាន
៥៧ អមតៈរុងរឿង
៥៨ ខ្មែរអង្គរ
៥៩ គន្ទាម
៦០ សំបូរណ៍
៦១ ទីបុត្តា
៦២ ស៊ី.ខេ
៦៣ វ៉ាយស្មាត
៦៤ សម្រឹត
៦៥ អង្គរ ឆព្វណ្ណ
៦៦ កាក់កប
៦៧ ស្មាយ
៦៨ សកល
៦៩ លើកស្ទួយ សមត្ថភាពគ្រួសារ
៧០ ព្រះច័ន្ទ
៧១ អូណ្ឌ
៧២ យូនីដា
៧៣ អេហ្វអេចអេហ្វ
៧៤ ប្លូ
៧៥ ខេមរា
៧៦ ខេមហ្វាន់ ប្រាថ្នា
៧៧ អេអេហ្វជី
៧៨ ម៉ាមេឌី
៧៩ វីរៈស័ក
៨០ វ៉ាឆា
៨១ ឥណទានមូលដ្ឋាន
៨២ សម្របសម្រួល
៨៣ ពិស្តុកា
៨៤ ប្រាក
៨៥ លីជូ
៨៦ អេ.លី.អិល.ភី.អិល
៨៧ ខេ អ៊ី ភី
៨៨ ពន្លឺស្នាមញញឹម
៨៩ រស្មីសិរីមង្គល
៩០ មេត្តា
៩១ អេហ្វធី ឃែស
៩២ រស្មីជ័យជំនះ
៩៣ រីករាយ
៩៤ ស៊ី.ខេ.អិល.អេស
៩៥ យូនីត្រាស់
៩៦ ជីប៊ីអាយធី
៩៧ ឥណទាន អភិវឌ្ឍន៍
៩៨ គ្រីស្តាល់
៩៩ អេស ប៊ី អ៊ី
១០០ ស៊ី.វី.អេ
១០១ អាខាបារ
១០២ រិទ្ធី
១០៣ សមធម៌
១០៤ ផាតនើរ
១០៥ រាហ៊្វ
១០៦ សុវណ្ណភូមិ សូសល
១០៧ ធិតិមា
១០៨ អេស.អិម.អ៊ី.អេស
១០៩ ផានីតដា
១១០ អូខិនដិន
១១១ វ៉ាយ ផ្លេស
១១២ ហ៊ប ហ្វាន់
១១៣ មរកត
១១៤ វី ស៊ីវីស
១១៥ ឧដុង្គ

### សាខាធនាគារជាតិនៃកម្ពុជា

១ ភ្នំពេញ
២ កំពង់ចាម
៣ ព្រះសីហនុ
៤ សៀមរាប
៥ បាត់ដំបង
៦ បន្ទាយមានជ័យ
៧ ស្វាយរៀង
៨ កណ្តាល
៩ កំពត
១០ កំពង់ធំ
១១ ពោធិ៍សាត់
១២ កំពង់ស្ពឺ
១៣ កោះកុង
១៤ រតនៈគិរី
១៥ ព្រៃវែង
១៦ តាកែវ
១៧ កំពង់ឆ្នាំង
១៨ ព្រះវិហារ
១៩ ក្រចេះ
២០ ស្ទឹងត្រែង
២១ មណ្ឌលគិរី

### អាជីវកម្មផ្សេងៗ

**អាជីវកម្មប្តូរប្រាក់: ៣.២០៣**

ភ្នំពេញ: ៦០
- អាជ្ញាប័ណ្ណ: ២១
- លិខិតអនុញ្ញាត: ៣៩

ខេត្ត: ៣.១៤៣
- អាជ្ញាប័ណ្ណ: ១
- លិខិតអនុញ្ញាត: ៣.១៤២

**១៤ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ**

១ ជីអិល ហ្វាយនែន
២ ប៊ីអេសភី ហ្វាយនែន
៣ មេហ្គា លីស៊ីង
៤ សួស្តី ហ្វាយនែន
៥ ខេខេហ្វាន់ លីស៊ីង
៦ តូយ៉ូតា ស៊ុយស៊ូ ហ្វាយនែន
៧ ម៉ូប៊ីលីធី
៨ ឆាយលីស រ៉ូយ៉ាល លីស៊ីង
៩ ខូម៉ាត់ស៊ុ លីស៊ីង
១០ គូបូតា លីស៊ីង
១១ អិល អូ ឌី
១២ អាយយ៉ែរ លីស៊ីង
១៣ ហ្វរវើដ លីស៊ីង
១៤ វី ស៊ីវីស លីស៊ីង

**៦ តតិយភាគី**

១ ក្រុមហ៊ុន Western Union
២ ក្រុមហ៊ុន Money Gram
៣ ក្រុមហ៊ុន Continental Exchange
៤ ក្រុមហ៊ុន Eurogiro A/S
៥ ក្រុមហ៊ុន Merchantrade Asia
៦ ក្រុមហ៊ុន ណូវើស ថេកណូឡូជី

**៣៣ គ្រឹះស្ថានផ្តល់សេវាទូទាត់**

១ ទ្រូ ម៉ាន់នី
២ លីហ្សូរ ផេ ប្រូ
៣ ផាយផេ
៤ អេស៊ា ឃែស
៥ ស៊ីធេល ហ្វាយនែនសល
៦ ស្តីត ផេ
៧ អាប៊ីត្រេវី ផេយ
៨ យូប៊ីល
៩ អ៊ីឌាល
១០ អាយផេ ៨៨
១១ បងឡួយ ផេម៉ិន
១២ ផានស៊ូ អ៊ិនធើណេសិនណល
១៣ ហួយ វ៉ន
១៤ អ៊ី-ម៉ាន់នី
១៥ ជ្រេហ្គនហ្វាយ
១៦ ដាយនែមីក
១៧ តារាសាគរ ផេ
១៨ បៃ សេន ថេកណូឡូជី
១៩ អ៊ែរទ្រីណូ គ្លូបល
២០ ផាវ៉ាហ្គន
២១ យេស អ៊ិននើវេសិន
២២ អិលអិម ផេ
២៣ វ៉ន ផេ ម.ក
២៤ លីន ផេ
២៥ យូ-ផេ
២៦ ស្តារផេ
២៧ ឡានតុន
២៨ វីង ម៉ាន់នី
២៩ គ្លីក ផេម៉ិន
៣០ សាន់ផេ
៣១ កែ ហ្វូ តុង ផេម៉ិន
៣២ ផេយ៉ុន
៣៣ ជីន ហុង ជិន

**១ ក្រុមហ៊ុនក្រេឌីតប្យូរ៉ូ**

១ ក្រេឌីតប្យូរ៉ូ (ខេមបូឌា)

# THE BANKING SYSTEM IN CAMBODIA (In June 2024)

## NATIONAL BANK OF CAMBODIA

### 59 COMMERCIAL BANKS

**28 Local Banks**

1 Foreign Trade
2 Cambodia Asia
3 Canadia
4 Vattanac
5 ACLEDA
6 Sathapana
7 Booyoung
8 PP Commercial
9 Cambodia Post
10 Chief
11 B.I.C
12 Prince
13 Chip Mong
14 Asia-Pacific
15 J Trust
16 PANDA
17 Agricultural and Rural
18 SME Bank
19 Alpha Commercial
20 SBI Ly Hour
21 Ruili
22 Wing
23 Heng He
24 Oriental
25 Bridge Bank Plc.
26 CCU
27 Heng Feng
28 IPU SEA

**11 Foreign Branch**

1 First Commercial
2 Krung Thai
3 Bank of China
4 Mega
5 ICBC
6 Taiwan
7 Bangkok
8 Kasikorn
9 Mizuho
10 Vietnam
11 Industrial bank of korea

**20 Subsidiary Banks**

1 Cambodian
2 Public
3 May Bank
4 J Trust Royal
5 Advanced Bank of Asia
6 Invest. & Devel.
7 Shinhan
8 RHB Bank
9 CIMB
10 SACOM
11 Hong Leong
12 Cathay
13 Union
14 Phillip
15 SHB
16 Bred
17 DGB
18 Woori
19 MB Bank
20 KB Prasac

### 9 Specialized Banks

**4 Locally Incorporated**

1 ANCO
2 Maritime
3 Evergrowth
4 Daun Penh

**5 Foreign Banks**

1 PHSME
2 KB Daehan
3 Angkor Capital
4 Aeon
5 Southern Capital

### 5 Representative Offices

1 Standard Chartered
2 Joint Stock Commercial
3 Sumitomo Mitsui
4 Shanghai
5 Export-Import

### 203 MICROFINANCE & RURAL CREDIT INSTISTUTION

**4 MDIs**

1 AMRET
2 AMK
3 LOLC
4 Mohanokor

**84 MFIs**

1 Seilanithih
2 Welcome
3 Maxima
4 Intean
5 Nong Hyup
6 Farmer
7 First Finance
8 Y.C.P
9 Samrithisak
10 Camma
11 Khemarak
12 Prime MF
13 Sonatra
14 Chamroeun
15 Active People
16 Bayon Credit
17 Borribo
18 Queen
19 City
20 Amatak
21 Sachak
22 ORO
23 Niron
24 Delta
25 Century
26 BAMC
27 PiphupThmey
28 Serey Oudom
29 Sambath
30 BNKC
31 Bamboo
32 Sahakrinpeap
33 Chailease royal
34 TBB
35 Royal
36 Sunny
37 Funan
38 Samporn Samakum
39 Samaky
40 Labor Care
41 CAM Capital Public
42 Kongkea Capital
43 Futaba
44 Idemitsu
45 Mothers
46 Sahaka
47 Golden Cash
48 Chokchey
49 Sabay
50 Jet's Cash Box
51 LED
52 L B P
53 Prasethpheap
54 T & Go
55 Anakut
56 Grow
57 Baitang
58 Mia
59 Leng Navatra
60 Vithey
61 Trop Khnhom
62 Khmer Capital
63 PG Development
64 JC
65 CMK
66 Rolya
67 LCH
68 Family
69 Propey
70 Sixty-Six
71 G B
72 Evergreen
73 Y.L.P
74 Sawad Rung Reung
75 Mango
76 Corich
77 Vivath Golden
78 Side Hustle
79 Soksan
80 AMZ
81 JACCS
82 East Micro Plc
83 RAFCO
84 HFC

**115 RCIs**

1 Chou Chivorn
2 Ministry of Rural
3 Bovor
4 Peayorb Finance
5 CEN Finance
6 Mittapheap
7 L.E.D.A Capital
8 LED-TIPS
9 DAIKOU
10 Preahkhan Aphivath
11 Krepo Finance
12 V.P Dec
13 Sereysuosdey Peanech
14 OCDAF Finance
15 Chor Meyjing
16 Hykean Capital
17 Kon Khmer Mongkul
18 Mean Chey Credit
19 Brosear
20 Meakea
21 KPCA
22 Dako
23 Samnang Protebatkar
24 Smile Capital
25 Kunapheap
26 Samreth Pech
27 B.Y.G Finance
28 Quick Amatak
29 LH
30 Baytang
31 K.D.O
32 Chum Samnang
33 CAM
34 Enteam Easy
35 Krong Khmer
36 Morodok Aphivath
37 Kalyan Aphivath
38 Phumin Credit
39 Virakboth
40 Punleu Kaksekar Khmer
41 ECK
42 S.H.G
43 R N D B
44 Phka Chhouk
45 Soksabay Heranhvatho
46 K.K.C.M
47 RADOCHICO
48 Prasithpheap Credit
49 Global Lending
50 LDA
51 Intean Neary
52 Pidaur Grow
53 Sky Light
54 Tara
55 Kon Kasekor
56 Kroursa Ennatean
57 Amatak Rongroeng
58 Khmer Angkor
59 Kuntheam
60 Sambo Trop
61 Tybotta
62 C.K
63 Right Smart
64 Samreth Credit
65 Angkor Chorpoan
66 Kakkorb
67 Smile
68 Sakal
69 Enatean Lerkstuoy Samatepheap Kruosa
70 Preah Chan
71 ONO
72 UNIDA
73 FHF Capital Plc
74 Blue
75 Khemra
76 CamFund Prathna
77 AFG
78 Mamede
79 Vireaksac
80 Racha
81 Aneaktean Molathan
82 Samrorb Samruol
83 Pishnuka
84 Prac
85 Lichou Capital
86 A.C.L.P.L
87 K E P
88 Punleu Snam Nhor Nhem
89 Reaksmey Serey Mongkul
90 Metta
91 FT Cash Express Plc
92 Reaksmey Chey Chumneas
93 Reakreay
94 C.K.L.S
95 Unitrust
96 GBIT
97 Entean Aphivath Achivkam
98 Crystal
99 S.B.E
100 C.V.A
101 ACABAR
102 Rithy
103 Samathor
104 Partner in Compassion Fund
105 Reahou
106 Sovannaphum Social Dev
107 Dhitemah
108 S.M.E.S ECO
109 Phanitda
110 OCKENDEN Metrei Entean
111 Right Place Rise Up
112 Hope Fund
113 Morakot
114 We Service
115 OUDONG

### NBC Provincial Branch

1 Phnom Penh
2 Kampong Cham
3 Sihanouk
4 Siemreap
5 Battambang
6 Banteay Meanchey
7 Svay Rieng
8 Kandal
9 Kampot
10 Kampong Thom
11 Pursath
12 Kampong Speu
13 Koh Kong
14 Ratanakiri
15 Prey Veng
16 Takeo
17 Kampong Chhnaing
18 Preah Vihear
19 Kratie
20 Stung Treng
21 Mondolkiri

### OTHERS BUSINESS

**Money Changer: 3,203**

| | |
|---|---|
| Phnom Penh: | 60 |
| • License: | 21 |
| • Authorisation: | 39 |
| Provincial: | 3,143 |
| • License: | 1 |
| • Authorisation: | 3,142 |

**14 Financial Leasing**

1 G.L. Finance
2 BSP Finance
3 Mega Leasing
4 Suosdey
5 KK Fund Leasing
6 TOYOTA Tsusho
7 Mobility Financing
8 Chailease Royal
9 Komatsu Leasing
10 Kubota Leasing
11 L O D Leasing
12 Icare Leasing
13 Forward Leasing
14 We Service Leasing

**6 Third Party Processor**

1 Western Union
2 Money Gram
3 Continental Exchange Solutions, Inc. dba RIA Financial Services
4 Eurogiro A/S
5 Merchantrade Asia
6 Novus Technologies

**33 Payment Service Institutions**

1 True Money
2 Ly Hour Pay Pro
3 Pi Pay
4 Asia Cash Express
5 Seatel Financial Service
6 Speed Pay
7 ARBITRARY PAY
8 Coolbill
9 Edeel
10 Ipay88
11 Bongloy Payments
12 Tian Xu International Technology
13 Huione Pay
14 E-Money Payment Solutions
15 Dragon fly
16 Dynamic
17 Dara Sakor
18 Bai Sen Technology
19 AETRINO GLOBAL
20 Paragon Payment
21 Kess Innovation
22 LM pay
23 One Pay Plc
24 Lync Pay Payment
25 U-Pay Digital
26 Starpay Fintech
27 Lanton International
28 Wing Money
29 Clik Payment
30 Sunpay
31 Cai Fu Tong
32 Payon
33 Jin Hong Zhen

**1 Credit Bureau**

1. CBC